មជ្ឈមណ្ឌលឯកសារកម្ពុជា

គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ
ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)
សិក្ខាសាលាជាមួយគ្រូបង្រៀន-ក្រុមការងារស្តីពីការចងក្រងឯកសារប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ
ប្រាសាទព្រះវិហារ ថ្ងៃទី ២៤-២៦ ខែធ្នូ ឆ្នាំ២០១០

# អត្ថបទពិភាក្សាទី៥

## ការកត់ត្រាពីបទពិសោធន៍របស់ជនជាតិចាមនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

*ដោយ សូ ហ្វារីណា*

*“មនុស្សចាស់គ្រប់រូបដែលស្លាប់ទៅ ប្រៀបដូចបណ្ណាល័យដែលឆេះបាត់បង់ដែរ”*

*សុភាសិតរបស់អាហ្វ្រិក*

### សេចក្តីផ្តើម

អត្ថបទនេះផ្តោតសំខាន់ទៅលើប្រវត្តិសាស្ត្រតាមរយៈការសួរនាំនៅក្នុងសហគមន៍ចាម រឿងរ៉ាវដែលបានមកពីការរៀបរាប់របស់ប្រជាជន សកម្មភាពរបស់គម្រោង និងការលំបាកនៃដំណើរការ ។ អត្ថបទនេះមិនពិភាក្សាច្រើនទៅលើការចងចាំដ៏ពេញលេញ ឬត្រឹមត្រូវនោះទេ ប៉ុន្តែពិភាក្សាទៅលើអ្វីដែលប្រជាជនចងចាំ និងផ្តល់អត្ថន័យទៅលើសាច់រឿងរបស់គាត់ ។ ការចងចាំរបស់ជនជាតិចាមដែលជាអ្នកនៅរស់រានមានជីវិតត្រូវបានរំឭកឡើងវិញនៅពេលដែលពេលវេលាកន្លងផុតទៅនិងទំនាក់ទំនងក្នុងសង្គម ។

ការកត់ត្រាប្រវត្តិសាស្ត្រជនជាតិចាមនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យបានធ្វើឡើងដោយសារមូលហេតុពីរយ៉ាង ។ ទីមួយ គឺដើម្បីលើកកម្ពស់ប្រវត្តិសាស្ត្ររបស់ប្រជាជនពលរដ្ឋនៅតាមសហគមន៍ដោយផ្តោតជាពិសេសទៅលើក្រុម ដែលមិនសូវត្រូវបានយកចិត្តទុកដាក់ឬបទពិសោធន៍របស់ពួកគាត់មិនសូវបានបញ្ចូលក្នុងការរៀបរាប់ជាទូទៅរបស់ប្រទេស ។ ទីពីរ គឺស្វែងយល់ពីការចងចាំឲ្យកាន់តែច្បាស់ និងការបង្ហាញចេញតាមរយៈមធ្យោបាយផ្សេងៗក្រោយមានជម្លោះនៅក្នុងសង្គម ។ ហេតុផលនោះគឺថាថ្វីត្បិតតែប្រវត្តិសាស្ត្រជាផ្លូវការនៃរបបកម្ពុជាប្រជាធិបតេយ្យមានសារសំខាន់ដោយឡែកក៏ដោយប៉ុន្តែ “ប្រវត្តិសាស្ត្រនៅ មិនទាន់គាស់កកាយឬនិយាយរួចហើយ”របស់ក្រុម ដែលមិន

ត្រូវបានយកចិត្តទុកដាក់ដូចជាជនជាតិចាមជួយពន្យល់ឲ្យកាន់តែច្បាស់នូវការពិតយ៉ាងទូលំទូលាយនៃបទពិសោធន៍ពិតតាមរយៈការបង្ហាញចេញផ្សេងៗ និងការបកស្រាយរបស់ពួកគាត់អំពីទំនាក់ទំនងសង្គមពីពេលមួយទៅពេលមួយទៀត ។

ការចងចាំនិងការរៀបរាប់ទាក់ទងគ្នាទៅវិញទៅមក ។ ការចងចាំធ្វើឲ្យមានការរៀបរាប់ពីបទពិសោធន៍ហើយត្រឡប់មកវិញ ការរៀបរាប់នេះហើយដែលជួយថែរក្សាការចងចាំ ។ តាមរយៈការនិទានរៀបរាប់អាចជួយរំឭកឡើងវិញនិងបង្ការកុំឲ្យភ្លេចភ្លាំង ។ ជាងនេះទៅទៀត ការប្រើប្រាស់ការចងចាំនិងការរៀបរាប់ដើម្បីបង្កើតចេញនូវរឿងរ៉ាវរបស់ពួកគាត់អាចជួយឲ្យសម្រេចធ្វើឡើងតាមរយៈកត្តាផ្សេងៗដូចជាវិធីសាស្ត្ររបស់អ្នកធ្វើបទសម្ភាសន៍វិធីរំឭករឿងរ៉ាវរបស់អ្នកផ្តល់បទសម្ភាសន៍ទំនាក់ទំនងរវាងអ្នកស្តាប់និងអ្នករៀបរាប់ និងបរិយាកាសជុំវិញការសម្ភាសន៍ ។ ដូចនេះ ប្រវត្តិសាស្ត្រតាមរយៈការសួរនាំ ឆ្លុះបញ្ចាំងទៅលើទំនាក់ទំនងទាំងអតីតកាលនិងបច្ចុប្បន្នកាលរបស់អ្នកផ្តល់បទសម្ភាសន៍និងជាមួយ បុគ្គលផ្សេងៗទៀតក្នុងសង្គម ។

ប្រវត្តិសាស្ត្រតាមរយៈការសួរនាំ គឺជាឧបករណ៍ដ៏សំខាន់ដើម្បីជួយបំពេញប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យឲ្យកាន់ពេញលេញ និងចូលរួមចំណែកដល់ចំណេះវិជ្ជាដែលមកពីការស្រាវជ្រាវទៅលើជនជាតិចាម ។ ប្រវត្តិសាស្ត្របែបនេះក៏អាចជួយបង្កើតឡើងវិញនូវអត្តសញ្ញាណជនជាតិចាម និងរួមចំណែកដល់ការកសាងសង្គមជាតិទាំងមូល ។ ដូចដែលលោក អាឡេសសាន់ដ្រូ ផតថែលលី (អ្នកស្រាវជ្រាវជាន់ខ្ពស់ផ្នែកប្រវត្តិសាស្ត្រតាមរយៈការសួរនាំ) អះអាងថា ការធ្វើបទសម្ភាសន៍អាចជួយអ្នកផ្តល់បទសម្ភាសន៍ ពង្រឹងភាពជាម្ចាស់ការ និងស្មារតីឲ្យបានល្អក្នុងការរំឭកអ្វីដែលបាត់បង់ទៅ និងរំឭកពីអត្តសញ្ញាណរបស់ខ្លួនឡើងវិញ ។ ការស្តាប់រឿងរ៉ាវក៏អាចជួយឲ្យយើងបង្កើនការអាណិតអាសូរដល់អ្នកផ្តល់សម្ភាសន៍ដែរ ។ ម្យ៉ាងទៀត ការទម្លាយការពិតរបស់អ្នកនិយាយរៀបរាប់ ក៏អាចធ្វើឲ្យគាត់បានអស់ចិត្តមួយកម្រិត ហើយជាលទ្ធផលអាចជួយដល់ការផ្សះផ្សាបានខ្លះដែរ ។

## ១. ប្រវត្តិសង្ខេបនៃគម្រោងប្រវត្តិសាស្ត្រតាមរយៈការសួរនាំ និងការអនុវត្តគម្រោង

ប្រវត្តិសាស្ត្រតាមរយៈការសួរនាំអាចជាមុខវិជ្ជាសិក្សា វិធីសាស្ត្រស្រាវជ្រាវ និងជាផលិតផលមួយ ។ ប្រវត្តិសាស្ត្រតាមការសួរនាំគឺជាការរួមបញ្ចូលគ្នានូវវិធីសាស្ត្រដែលបានមកពីមុខវិជ្ជាមួយចំនួនដូចជា សង្គមវិទ្យា នរវិទ្យា ចិត្តវិទ្យា និងភាសាវិទ្យា ដើម្បីសិក្សាឲ្យកាន់តែច្បាស់ពីការរៀប រាប់តាមរយៈការចងចាំ ។ តាមវិធីសាស្ត្រ ប្រវត្តិសាស្ត្រតាមរយៈការសួរនាំត្រូវបានរកឃើញដំបូងបង្អស់ដោយ លោក អាឡែន នេវីន សាស្ត្រាចារ្យនៅសាកលវិទ្យាល័យខូឡំបៀរនៅទសវត្សរ៍ឆ្នាំ១៩៤០ ។ នេវីនបានកត់ត្រារឿងរ៉ាវរបស់ក្រុមអភិជនស្បែកសក្នុងអំឡុងពេលសង្គ្រាមលោកលើកទី២ ។ ក្រោយ

មកនៅ ទសវត្សរ៍ឆ្នាំ ១៩៥០ លោក ប៉ូល ថមសុន បានស្រាវជ្រាវបន្ថែមលើសពីនេះទៀត ដោយគាត់បានធ្វើបទសម្ភាសន៍ ទៅលើក្រុមវណ្ណៈកម្មករនិងប្រជាជនសាមញ្ញនៅក្នុងប្រទេសអង់គ្លេស ។ នៅក្នុងការស្រាវជ្រាវរបស់លោក អ្នកដែលត្រូវធ្វើបទសម្ភាសន៍ត្រូវបានយល់ថា ជាប្រវត្តិសាស្ត្ររស់ និងជាឃ្លាំងផ្ទុកព័ត៌មាន ព្រឹត្តិការណ៍ និងហេតុការណ៍ដ៏សម្បូរបែប ។ ចាប់តាំងពីពេលនោះមក ប្រវត្តិសាស្ត្រតាមរយៈការសួរនាំត្រូវបានប្រើប្រាស់ជាសាកលដោយអ្នកស្រាវជ្រាវជាន់ខ្ពស់ស្ទើរគ្រប់ជំនាញ ។ វិធីសាស្ត្រនេះត្រូវបានប្រើប្រាស់ដោយក្រុម អភិរក្សសារមន្ទីរ ក្រុមអ្នកសិល្បៈឬក្រុមជំនាញខាងប្រព័ន្ធផ្សព្វផ្សាយ ដើម្បីបង្កើតជាឯកសារ ប្រវត្តិសាស្ត្រ ដែលរួមបញ្ចូលទាំងសំឡេង រូបភាពនិងអត្ថបទ ។

ជាផលិតផលមួយប្រវត្តិសាស្ត្រតាមរយៈការសួរនាំត្រូវបានធ្វើឡើងតាមរយៈបទសម្ភាសន៍ឬការសន្ទនាគ្នាពីបទពិសោធន៍ឬព្រឹត្តិការណ៍ដែលបានកើតឡើងពីអតីតកាល ។ បទសម្ភាសន៍ទាំងនោះអាចស្ថិតក្នុងទម្រង់ផ្សេងគ្នាជាលក្ខណៈបោះពុម្ពផ្សាយឬមិនត្រូវបានបោះពុម្ពផ្សាយជាសាធារណៈ ។

### ក. ចេញពីកម្រងសំណួរទៅជាបទសម្ភាសន៍

មជ្ឈមណ្ឌលឯកសារកម្ពុជា បានចាប់ផ្តើមអនុវត្តគម្រោងប្រវត្តិសាស្ត្រតាមរយៈការសួរនាំនៅឆ្នាំ ២០០៥ ដោយមានការយល់ស្របមតិពីសំណាក់តំណាងស្ត្រីចាម និងក្រុមអ្នកដឹកនាំសាសនាក្នុងសហគមន៍ចាម ។ គម្រោងនេះធ្វើការកត់ត្រាបទពិសោធន៍របស់សហគមន៍ចាមក្រោមរបបខ្មែរក្រហម ដោយបម្រើឲ្យគោលបំណងមួយចំនួនដូចជាជំរុញឲ្យមានការពិភាក្សានិងជជែកវែកញែកពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងចូលរួមដល់ការបង្កើតចំណេះដឹងតាមការស្រាវជ្រាវ ហើយនិងជួយលើកស្ទួយសិទ្ធិស្ត្រីចាមជាសាធារណៈ ព្រមទាំងកម្មវិធីផ្សព្វផ្សាយនៅតាមមូលដ្ឋាន ។ គោលបំណងរបស់គម្រោងជារួម គឺដើម្បីថែរក្សា ការចងចាំរបស់សហគមន៍ចាម និងលើកកម្ពស់ដំណើរការស្វែងរកការពិត យុត្តិធម៌ ការផ្សះផ្សា និងជំរុញឲ្យមានការអប់រំអំពើប្រល័យពូជសាសន៍ ។

នៅឆ្នាំ២០០៥ មជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើការប្រជុំជាមួយអ្នកដឹកនាំសហគមន៍ចាមចំនួនជាង១០០នាក់នៅការិយាល័យរបស់ខ្លួនក្នុងទីក្រុងភ្នំពេញ ។ យើងក៏បានធ្វើការប្រជុំ៣លើកបន្ទាប់មកទៀត ជាមួយអ្នកដឹកនាំសហគមន៍និងតំណាងស្ត្រីចាមនៅទីតាំងចំនួន៣ក្នុងខេត្តព្រះសីហនុខេត្តបាត់ដំបង និងខេត្តកំពង់ចាម ។ អ្នកចូលរួមទាំងអស់បានគាំទ្រគម្រោងប្រមូលចងក្រងឯកសាររបស់ជនជាតិចាមហើយបានសន្យាថានឹងផ្តល់ការគាំទ្រកាន់តែខ្លាំងថែមទៀត ។ កម្រងសំណួរចំនួន៣០ច្បាប់ត្រូវបានចែកជូនដល់អ្នកតំណាងម្នាក់ៗ ដើម្បីឲ្យពួកគាត់ធ្វើការចែកជូនដល់សមាជិករបស់ខ្លួនឲ្យជួយ

បំពេញនៅពេលត្រឡប់ទៅមូលដ្ឋានវិញ ។ ក្រោយមក គារាងស្ទាបស្ទង់មតិចំនួន១៤០ច្បាប់ដែលបានបំពេញរួចបានត្រូវប្រមូលមកវិញ ដែលភាគច្រើនបានបំពេញពេញលេញនិងចប់សព្វគ្រប់ ។

ខ្ញុំបានយោងទៅលើបញ្ជីឈ្មោះហាកិម (ចៅក្រមនិងជាអ្នកដឹកនាំសហគមន៍មូលដ្ឋាន) និងវិហារអ៊ីស្លាម នៅទូទាំងប្រទេសដែលខ្ញុំបានទទួលពីក្រុមប្រឹក្សាជាន់ខ្ពស់សម្រាប់កិច្ចការសាសនាអ៊ីស្លាមនៅក្នុងប្រទេសកម្ពុជា (មូហ្វទី) នៅដែលខ្ញុំបានចុះទៅស្រាវជ្រាវដល់មូលដ្ឋាន ។ បញ្ជីនោះជួយឲ្យយើងយល់ដឹងពីទីតាំងភូមិសាស្ត្ររបស់វិហារអ៊ីស្លាមនិងសហគមន៍ចាមនៅក្នុងប្រទេសកម្ពុជា ។យើងក៏បានប្រើប្រាស់វិធីសាស្ត្រផ្សេងៗទៀត ដើម្បីស្វែងរកស្ត្រីចាម ។ ជាដំបូងខ្ញុំបានធ្វើបទសម្ភាសន៍ជាមួយស្ត្រីមួយចំនួនដែលធ្លាប់ចូលរួមក្នុងកិច្ចប្រជុំនៅឯមជ្ឈមណ្ឌលឯកសារកម្ពុជានិងនៅតាមបណ្តាខេត្តមួយចំនួនបន្ទាប់មក ខ្ញុំបានសុំពួកគាត់ឲ្យជួយណែនាំអ្នកដែលខ្ញុំអាចសាកសួរព័ត៌មានបានហើយខ្ញុំក៏បានសួរហាកិមឲ្យជួយណែនាំជនជាតិចាមផ្សេងទៀត ដែលមាន បំណងចង់ចែករំលែករឿងរ៉ាវរបស់ពួកគាត់ ។

នៅចន្លោះឆ្នាំ២០០៨ និង ឆ្នាំ២០០៩ ក្រុមគម្រោងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើបទ សម្ភាសន៍ជាមួយសមាជិកសហគមន៍ចំនួន៥០០នាក់ រួមមាន ហាកិម គ្រូបង្រៀនសាសនាស្ត្រី និង យុវជន ដែលក្នុងនោះបទសម្ភាសន៍ចំនួន៤០០ ត្រូវចម្លងចេញ ដែលមានចំនួនប្រហែល ៩៧/៣២ទំព័រ ។ ស្ត្រីទាំងនោះ បានប្រគល់វត្ថុបុរាណមួយចំនួនដែលពួកគាត់បានថែរក្សាទុកនៅសម័យខ្មែរក្រហម ដូចជា ដាវ ចាន ចាស គីតាបចាស់ៗ (សៀវភៅបង្រៀនសាសនាអ៊ីស្លាម) និងរូបថតចាស់ៗ ។

មុនពេលចុះទៅធ្វើការនៅមូលដ្ឋានខ្ញុំបានចូលរួមវគ្គបណ្តុះបណ្តាលអំពីវិធីសាស្ត្រស្រាវជ្រាវដែលបង្រៀនពីជំនាញស្រាវជ្រាវនិងរបៀបធ្វើបទសម្ភាសន៍ នៅការិយាល័យស្រាវជ្រាវអំពីប្រវត្តិសាស្ត្រតាមការសួរនាំនៃសកលវិទ្យាល័យខូលំបៀរនារដ្ឋវក្តៅ ។ ចំណេះដឹងនិងជំនាញដែលខ្ញុំបានទទួលពីវគ្គបណ្តុះបណ្តាលនៅវិទ្យាស្ថាននេះ ជាមួយសាស្ត្រាចារ្យ រ៉ូណាល គ្រេលី (Ronald Grele) អតីតប្រធានសមាគមប្រវត្តិសាស្ត្រតាមការសួរនាំរបស់សហរដ្ឋអាមេរិករួមទាំងសាស្ត្រាចារ្យល្បីៗជាច្រើនរូបទៀត ដែលបានជួយបង្ហាត់បង្រៀនខ្ញុំឲ្យកាន់តែយល់ដឹងថែមទៀតពីវិធីសាស្ត្រ និងទ្រឹស្តីនៃការប្រមូលប្រវត្តិសាស្ត្រតាមការសួរនាំ ។

ដើម្បីធ្វើការស្វែងយល់ពីការងារជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ខ្ញុំបានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីហេតុការណ៍រន្ធត់ចម្បងនិងដោយប្រយោល និងវិធីសាស្ត្រជួយខ្លួនឯង ដែលរៀបចំដោយអង្គការចិត្តសង្គមអន្តរវប្បធម៌ ដែលជាអង្គការនាំមុខគេខាងជំនាញចិត្តសាស្ត្រ និងបញ្ហាផ្លូវចិត្តនៅក្នុងប្រទេសកម្ពុជា ។

សម្រាប់គម្រោងនេះ ខ្ញុំបានប្រើប្រាស់ទាំងទម្រង់បទសម្ភាសន៍ដែលបានគ្រោងទុកជាមុននិងទម្រង់បទសម្ភាសន៍ដែលឥតព្រៀងទុក ដោយរួមមានប្រធានបទជាច្រើននៅក្នុងនោះ ដែលនេះអាចឲ្យយើងបត់បែនស្រួលក្នុងពេលកំពុងធ្វើបទសម្ភាសន៍ ។ ទម្រង់បទសម្ភាសន៍គ្រោងជាមុនជួយឲ្យខ្ញុំផ្តោតទៅលើប្រធានបទ និងទុកឱកាសដល់អ្នកចូលរួមផ្តល់អត្ថន័យជាក់លាក់ ។ ទម្រង់បទសម្ភាសន៍ដែលមិនបានគ្រោងទុកជាមុនអនុញ្ញាតឲ្យមានចម្លើយវែង និងផ្តល់សេរីភាពដល់ស្ត្រីដើម្បីបញ្ចេញសំឡេងបានទូលំទូលាយ ។ ដូចនេះ ការធ្វើបទ សម្ភាសន៍ដែលមានលក្ខណៈស៊ីជម្រៅ នឹងអាចសម្រេចទៅបាន ។ ទម្រង់ទាំងពីខាងលើនេះ បង្ហាញចេញ នូវទស្សនៈរស់រវើកនិងងាយស្រួលបត់បែន ដែលជួយឲ្យយើងគ្រប់គ្រងការផ្លាស់ប្តូរភ្លាមៗក្នុងពេលសម្ភាសន៍បាន ។ យើងមិនត្រូវមើលស្រាលនូវរាល់ការផ្លាស់ប្តូរផ្សេងៗដែលមានពេលចុះស្រាវជ្រាវនៅមូលដ្ឋានឡើយ ។ ដូច្នេះ ភាពបត់បែនគឺជាកិច្ចការសំខាន់បំផុត ។ នៅក្នុងករណីខ្លះ ទោះបីជាខ្ញុំបានប្រើកម្រងសំណួរនៅពេលធ្វើបទសម្ភាសន៍ក៏ដោយ ប៉ុន្តែការធ្វើបទសម្ភាសន៍ជាក់ស្តែង បានឃ្លាតចេញពីប្រធានបទជាក់លាក់ខ្លះដែរ ដើម្បីសម្រួលដល់អ្នកផ្តល់បទសម្ភាសន៍ក្នុងការបញ្ចេញមតិរបស់ពួកគាត់ឲ្យបានទូលាយ ។ ក្នុងពេលធ្វើបទសម្ភាសន៍ជនជាតិចាមខ្លះបានចាប់ផ្តើមដោយបង្ហាញពីអំពើឃោរឃៅរបស់ខ្មែរក្រហម ។ អ្នកខ្លះទៀតបាននិយាយពីរឿងរ៉ាវជីវិតរបស់ខ្លួនដែលផ្តើមចេញពីជីវិតជាកុមារភាពរហូតដល់ជីវិតបច្ចុប្បន្នខណៈដែលអ្នកផ្សេងទៀតបានចាប់ផ្តើមជាមួយនឹងការរំឭកឡើងវិញពីការបាត់សមាជិកគ្រួសាររបស់ខ្លួន ។

បទសម្ភាសន៍ភាគច្រើនត្រូវបានវាយបញ្ចូលទៅក្នុងកំព្យូទ័រ និងរៀបចំដាក់ទុកជាឯកសាររួមជាមួយរូបថត កំណត់ត្រាផ្សេងៗព្រមទាំងលេខទាក់ទងរបស់អ្នកផ្តល់បទសម្ភាសន៍ដោយប្រើប្រាស់ប្រព័ន្ធកាតាឡុករបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងទូឯកសារដែលបិទជិត ។ បទសម្ភាសន៍មួយចំនួនត្រូវបានសរសេរចេញជាសាច់រឿង ហើយបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្តីស្វែងរកការពិត និងការបោះពុម្ពផ្សេងទៀត ។ បណ្ណសារទាំងនេះ ត្រូវបានដាក់ឲ្យប្រើប្រាស់ជាសាធារណៈដែលផ្តល់ផលប្រយោជន៍ដល់អ្នកចង់ដឹងដើម្បីធ្វើការស្រាវជ្រាវ ហើយសម្រាប់ការរាយការណ៍អំពីការងាររបស់ពួកគេព្រមទាំងសម្រាប់ក្រុមដែលមានចំណាប់អារម្មណ៍ទៅលើជនជាតិចាម ។

## ខ. ផ្សារភ្ជាប់យុវជនជាមួយឪពុកម្តាយនិងមនុស្សជំនាន់ចាស់

កម្មវិធីបន្ទាប់ដែលចូលរួមចំណែកដល់ការបង្កើតប្រវត្តិសាស្ត្រគឺការប្រឡងប្រជែងសរសេរសំណេរ ។ គោលបំណងរបស់កម្មវិធីនេះគឺដើម្បីផ្សារភ្ជាប់យុវជនជាមួយគម្រោងនិងបង្កើនចំណងទាក់ទង ជាមួយ ឪពុកម្តាយឲ្យកាន់តែប្រសើរឡើង តាមរយៈការសន្ទនា ក៏ដូចជាធ្វើឲ្យជំនាញសរសេរ

របស់ពួកគេកាន់តែល្អឡើង ។ កម្មវិធី នេះអនុញ្ញាតឲ្យយុវជនអ៊ីស្លាមរៀនសូត្រអំពីការប្រមូលសាច់រឿងប្រវត្តិសាស្រ្ត ដោយឲ្យពួកគេចាប់ផ្តើមជាមួយឪពុកម្តាយនិងរៀនសូត្រមេរៀនខ្លះៗ ។

នៅខែមីនា ឆ្នាំ២០០៧ គម្រោងប្រវត្តិសាស្រ្តតាមរយៈការសួរនាំ បាននាំយកយុវជនមុស្លីមចំនួន១០០មកពីខេត្តក្រុងមួយចំនួនក្នុងប្រទេសកម្ពុជាដើម្បីចូលរួមក្នុងកម្មវិធីអប់រំដោយរួមមានការធ្វើទស្សនកិច្ចទៅកាន់ទីតាំងប្រល័យពូជសាសន៍ និងបន្ទប់សវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ អ្នកចូលរួមភាគច្រើនគឺជានិស្សិតសកលវិទ្យាល័យដែលមានអាយុលើស១៨ឆ្នាំឡើង ។ ក្នុងអំឡុងពេលដំណើរទស្សនកិច្ចបទសម្ភាសន៍ជាច្រើនត្រូវបានធ្វើឡើងដើម្បីប៉ាន់ប្រមាណពីទស្សនៈយល់ដឹងរបស់យុវជនទៅលើរបបខ្មែរក្រហមនិងប្រធានបទផ្សេងៗទៀតដូចជា ការទប់ស្កាត់អំពើប្រល័យពូជសាសន៍វិធីសាស្រ្តដើម្បីពង្រឹងការផ្សះផ្សា នៅក្នុងប្រទេសកម្ពុជា ។

នៅឯសារមន្ទីរទួលស្លែងនិងបូជនីយដ្ឋានជើងឯកសិស្សទាំងអស់បានឃើញរូបភាពជាច្រើនដែលរំឭកអំពីអំពើឃោរឃៅដែលបានប្រព្រឹត្តដោយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។ រូបភាពទាំងនោះរួមមាន រូបថតអ្នកទោសជាច្រើនពាន់សន្លឹក រណ្តៅសាកសព បន្ទប់ឃុំឃាំងដែលមានស្នាម ប្រឡាក់ឈាមនិងឧបករណ៍ធ្វើទារុណកម្ម ។ អ្នកដឹកនាំគម្រោងបានផ្តល់ការណែនាំនិងវិធី ដើម្បីរៀបចំឲ្យមានប្រវត្តិសាស្រ្តតាមការសួរនាំជាមួយឪពុកម្តាយរបស់ពួកគេ និងឆ្លើយសំណួរនីមួយៗដែលនិស្សិតមាន ។ ក្នុងការផ្សារភ្ជាប់យុវជនជាមួយ ឪពុកម្តាយ សិស្សម្នាក់ៗត្រូវបានស្នើឲ្យសម្ភាសម្តាយឬឪពុក ឬសាច់ញាតិម្នាក់អំពីបទពិសោធន៍របស់ពួកគាត់នៅក្នុងរបបប្រល័យពូជសាសន៍ហើយសរសេរចេញជាសំណេរមួយ ។ នៅក្នុងសំណេរសិស្សត្រូវបានជំរុញឲ្យបង្ហាញពីទស្សនៈរបស់ខ្លួនទៅលើរបបខ្មែរក្រហម ។

សិស្សម្នាក់ឬបេក្ខជនម្នាក់ៗបានទទួលឯកសារមួយកញ្ចប់រួមមានទស្សនាវដ្តីស្វែងរកការពិតមួយច្បាប់ សេចក្តីណែនាំសម្រាប់ការប្រមូលសាច់រឿងមួយច្បាប់ (ដែលមាននៅក្នុងសេចក្តីបន្ថែមខាងក្រោម) ប៊ិចមួយដើម និងសៀវភៅសរសេរមួយក្បាល ។

បន្ទាប់ពីសេចក្តីប្រកាសលើកដំបូងនិងការតឿនរំឭកជាបន្តបន្ទាប់សំណេរចំនួន៤៧ច្បាប់ត្រូវបានដាក់បញ្ចូលក្នុងការប្រឡងប្រជែង ដែលក្នុងនោះមានសំណេរមកពីសិស្សស្រី២៦នាក់ និងមកពីសិស្សប្រុស២១ ដែលមកពីខេត្តក្រចេះ កំពង់ចាម ពោធិសាត់ កណ្តាល កំពង់ធំ កំពង់ឆ្នាំង កំពត កែប និងភ្នំពេញ ។ សិស្សទាំងនោះបានផ្ញើសំណេរតាមរយៈអ្នកដឹកនាំសហគមន៍ គ្រូបង្រៀនសាសនាអ៊ីស្លាម ក្រុមគ្រួសាររបស់គេ ឬពួកគេយកមកដោយផ្ទាល់ ។ សំណេរទាំង១០ត្រូវបានជ្រើសរើសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ ដូចខាងក្រោម ៖ (១) ភាពស្មោះត្រង់ក្នុងការសរសេរ (២) បែបផែននិងភាសាសរសេរ (៣)គំនិតប្រទាក់ក្រឡា គ្នានិងការបញ្ចូលទស្សនៈរបស់ខ្លួនទៅលើរបបខ្មែរក្រហម (៤)

ការច្នៃប្រឌិតប្រកបដោយគំនិត(៥) ការប្រើប្រាស់វេយ្យាករណ៍និងប្រកបពាក្យបានត្រឹមត្រូវ ។ នៅខែមេសា ឆ្នាំ២០០៨ អ្នកដែលទទួលជ័យជម្នះ ទទួលបានរង្វាន់ពិសេសនៅក្នុងពិធីជួបជុំតូចមួយ ។ សំណេររបស់គេចំនួន៨ត្រូវបានចុះផ្សាយក្នុងទស្សនាវដ្តី ស្វែងរកការពិត ហើយនិស្សិតមួយចំនួនក៏ត្រូវបានសម្ភាសន៍ដោយសារព័ត៌មានក្នុងស្រុក ។

ជាទូទៅស្ត្រីដែលជាម្តាយគឺជាអ្នកដែលនិយាយប្រាប់កូនចៅជំនាន់ក្រោយពីបទពិសោធន៍របស់ខ្លួនឬបទពិសោធន៍ក្រុមគ្រួសារយ៉ាងមានប្រសិទ្ធិភាពដោយសារតែពួកគាត់នៅជិតកូនចៅរបស់ខ្លួនជាង ។ បុរសដែលជាប្តីមិនសូវមានពេលវេលាគ្រប់គ្រាន់ដើម្បីចែករំលែកបទពិសោធន៍របស់ខ្លួនជាមួយកូនចៅទេ ។ ដូច្នេះ ក្នុងនាមជាអ្នកនិយាយរឿងស្ត្រីប្រាប់សាច់រឿងខ្លីៗ ឬអប់រំកូនចៅឲ្យចេះសន្សំសំចៃនិងធ្វើអំពើល្អជារឿយៗ ។

សាច់រឿងនៅក្នុងសំណេរមានភាពស្រដៀងគ្នាច្រើន ដោយសិស្សទាំងអស់បានសរសេរអំពីការជម្លៀសនិងការដូរទីតាំងក្នុងទ្រង់ទ្រាយធំលក្ខខណ្ឌធ្វើការងារដ៏លំបាក ការភ័យខ្លាចជាញឹកញាប់ ការខ្វះអាហារការតស៊ូ ក្នុងការប្រណិបត៍សាសនាអ៊ីស្លាម ភាពរឹតត្បិតក្នុងទំនាក់ទំនងរបស់សមាជិកគ្រួសារនិងការសម្លាប់ ។ បន្ថែមទៅលើបទពិសោធន៍របស់ឪពុកម្តាយ សិស្សជាច្រើនបាន សរសេរអំពីគំនិតផ្ទាល់ខ្លួនអំពីកត្តាមួយចំនួន ដែលធ្វើឲ្យមានយុត្តិធម៌សម្រាប់ឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ហើយថាតើអំពើប្រល័យពូជសាសន៍ត្រូវបានការពារដោយរបៀបណានៅពេលអនាគត ។ ដើម្បីបញ្ជាក់ពីការលើកឡើងទាំងនេះ ការណ៍សំខាន់គឺត្រូវពិនិត្យមើលឧទាហរណ៍ពីរខាងក្រោម ៖

ពីដំបូង សុទ្ធ ណាសៀត មានការលំបាកណាស់ក្នុងការសុំឲ្យម្តាយរបស់គាត់និយាយអំពីជីវិតរបស់ខ្លួនក្រោមរបបខ្មែរក្រហម ។ បន្ទាប់ពីការព្យាយាមរបស់គាត់ពីរ-បីលើកមកម្តាយរបស់គាត់ចាប់ផ្តើមនិយាយបណ្តើរហើយយំបណ្តើរ ។ នៅពេលដែលទឹកភ្នែករបស់គាត់ហូរចុះគាត់ចាប់ផ្តើមរៀប រាប់ពីបទពិសោធន៍របស់គាត់ដោយយឺតៗ នៅចំពោះមុខកូនប្រុសរបស់គាត់ ។ ណាសៀត បានសរសេរថា ៖

> នៅទីបំផុត ខ្ញុំអាចជំរុញឲ្យម្តាយរបស់ខ្ញុំនិយាយប្រាប់ខ្ញុំនូវអ្វីដែលបានកើតឡើង ។ ទឹកភ្នែកធ្លាក់ចុះលើថ្ពាល់របស់គាត់ ហើយខ្ញុំអាណិតគាត់ខ្លាំងណាស់ ។ ខ្ញុំស្ថិតក្នុងស្ថានភាពលំបាកដោយសារ ខ្ញុំមិនអាចយល់ពីទំហំនៃការឈឺចាប់របស់គាត់ ។ ខ្ញុំសង្កេតឃើញថា គាត់បានលាតត្រដាងនូវអតីតកាលរបស់គាត់ ពីព្រោះគាត់ជឿជាក់ថា ការបង្រៀនក្មេងជំនាន់ក្រោយអំពីភាពឃោរឃៅ របស់ខ្មែរក្រហមគឺជារឿងសំខាន់ ។

នៅក្នុងអំឡុងរបបខ្មែរក្រហម ម្ដាយរបស់ ណាសៀត ត្រូវបានចាប់ខ្លួនហើយដាក់ក្នុងមន្ទីរឃុំឃាំង ។ បទឧក្រិដ្ឋដែលខ្មែរក្រហមបានចោទប្រកាន់គឺចេញមកពីការរត់គេចខ្លួនទៅកាន់ទន្លេម្ខាងទៀតដើម្បីស្វែងរកអាហារដោយសារគាត់អត់ឃ្លាន ។ គាត់ក៏ត្រូវចាប់បានហើយបញ្ជូនទៅដាក់មន្ទីរឃុំឃាំងជាបន្ទាន់ដោយគ្មានសួរចម្លើយ ។ នៅក្នុងគុកដៃរបស់គាត់ទាំងពីរជាប់ខ្នោះ ហើយគាត់ទទួលបានតែបបររាវពីរពេលប៉ុណ្ណោះក្នុងមួយថ្ងៃ ។ គាត់ក៏ត្រូវបានបង្ខំឲ្យធ្វើពលកម្មទាំងបង្ខំ ដែលគាត់ស្ទើរតែមិនអាចទ្រាំទ្របាន ។ យោងតាមម្ដាយរបស់ណាសៀត សាកសពអ្នកទោសជាច្រើនត្រូវបាននាំចេញពីមន្ទីរឃុំឃាំង ជារៀងរាល់ថ្ងៃ ។ គាត់ជឿថា វេនរបស់គាត់ក៏នឹងមកដល់ឆាប់ៗដែរ ។ សំណាងល្អបី-បួនខែ ក្រោយមក គាត់ត្រូវបានដោះលែងឲ្យមានសេរីភាពបន្ទាប់ ពីប្រធានភូមិរបស់គាត់បានបញ្ជាក់ថា គាត់គឺជាមនុស្ស ស្មោះត្រង់ ដោយមិនក្បត់អង្គការ ។

សិស្សម្នាក់ទៀតដែលមានឈ្មោះថា យ៉ាគីន បានសរសេរអំពីរឿងរ៉ាវឪពុករបស់ខ្លួន ។ យ៉ាគីននិយាយថា «វាមានការលំបាកណាស់ក្នុងការបំភ្លេចនូវបទពិសោធន៍ដ៏ជូរចត់ប្រសិនយើងមិនបានជួបប្រទះផ្ទាល់» ។ ឪពុករបស់ យ៉ាគីន បានបាត់បង់ក្រុមគ្រួសារទាំងមូលនៅក្នុងរបបនោះ ។ សព្វថ្ងៃនេះគាត់រស់នៅ ក្នុងភូមិជាមួយអ្នកដែលគាត់ជឿថាបានសម្លាប់បងប្រុសរបស់គាត់ ។ យ៉ាគីន ជឿថាពេលវេលានិងការបង្ហាត់បង្រៀនតាមសាសនាអាចជួយកាត់បន្ថយការឈឺចាប់និងកំហឹងរបស់ឪពុកខ្លួន ។ យ៉ាគីន សរសេរថា ៖

> គាត់មិនដែលបានប្រាប់រឿងរ៉ាវអំពីមនុស្សម្នាក់នោះសោះ ប៉ុន្តែខ្ញុំដឹងថា គាត់មានការឈឺចាប់ ។ ខ្ញុំ សង្ឃឹមថា ពេលវេលានិងសុភមង្គលក្នុងគ្រួសារនឹងជួយឲ្យគាត់បានធូរស្បើយ ។ ហើយប្រហែលជាកាន់តែប្រសើរ ប្រសិនបើមនុស្សនោះចេញមកសារភាពឬសុំទោសនៅចំពោះមុខគាត់ដោយហេតុថាអ៊ីស្លាមបង្រៀនមនុស្សឲ្យយើងចេះអត់ឱនឲ្យគ្នា និងជំរុញឲ្យមនុស្សចេះទទួលស្គាល់នូវកំហុសរបស់ខ្លួន ។ សម្រាប់ខ្ញុំ ប្រសិនបើខ្ញុំបានដឹងថា មនុស្សនោះជា អ្នកណា ខ្ញុំប្រហែលជាខឹងសម្បាពីដំបូង ប៉ុន្តែនឹងធូរស្បើយនៅពេលក្រោយ ។

សំណេរទាំងអស់ក៏ផ្ដោតសំខាន់ទៅលើគោលគំនិតយុត្តិធម៌និងការផ្សះផ្សា ។ យុវជនមួយចំនួនបានកំណត់ន័យយុត្តិធម៌ថា ជាភាពស្មោះត្រង់និងមិនលម្អៀង ខណៈដែលយុវជនផ្សេងទៀតភ្ជាប់ពាក្យនេះទៅនឹងភាពស្មើគ្នានៅចំពោះមុខច្បាប់ ។ យោងតាមយុវជនមួយចំនួននៅពេល ដែលយុត្តិធម៌

សម្រេចបានដំណើរឆ្ពោះទៅរកការផ្សះផ្សាអាចចាប់ផ្ដើមបាន ។ យុវជនផ្សេងទៀតបានគិតថា នៅពេលដែលការសុំទោសធ្វើឡើងការអត់ឱនអាចនឹងធ្វើទៅរួច ហើយការផ្សះផ្សារវាងជនរងគ្រោះ និងជនដៃដល់អាចកើតឡើង ។

ការប្រកួតប្រជែងសរសេរនេះបង្ហាញចេញនូវសារសំខាន់នៃវិធីសាស្ត្រប្រមូលសាច់រឿងប្រវត្តិសាស្ត្រតាមមធ្យោបាយពីរយ៉ាង ៖ ការអប់រំនិងការកសាងទំនាក់ទំនង ។ នៅពេលដែលសិស្សស្ដាប់ឪពុកម្ដាយរបស់ពួកគេនិយាយប្រាប់អំពីស្ថានភាពដ៏លំបាកក្រោមរបបខ្មែរក្រហមពួកគេមិនត្រឹមតែរៀនសូត្រពីបទពិសោធន៍ របស់ឪពុកម្ដាយប៉ុណ្ណោះទេ ថែមទាំងយល់ដឹងពីឪពុកម្ដាយកាន់តែប្រសើរឡើង ។ សិស្សមួយចំនួនបានសរសេរថា ការសរសេរអំពីបទពិសោធន៍របស់ឪពុកម្ដាយគឺជាលំហាត់ដ៏សំខាន់ពីព្រោះវាបានជួយឲ្យពួកគេ យល់ពីការលំបាកនិងកោតសរសើរចំពោះឪពុកម្ដាយដែលបានឆ្លងផុតពីរបបនោះហើយថែមទាំងបានចិញ្ចឹមបីបាច់ពួកគេឲ្យបានធំធាត់ ។ សិស្សម្នាក់មកពីខេត្តកំពង់ធំនិយាយថា "មុនពេលខ្ញុំបានចូលប្រឡូកក្នុងការសរសេរ ម្ដាយខ្ញុំប្រាប់ខ្ញុំតិចតួចអំពីបទពិសោធន៍របស់គាត់ ។ បន្ទាប់ពីនោះមក ខ្ញុំបានដឹងច្រើនពីការតស៊ូរបស់គាត់ ។ តហៀវ ដែលមកពីខេត្តកំពតទទួលស្គាល់ថាគាត់កាន់តែចាប់អារម្មណ៍ពីរបបខ្មែរក្រហម បន្ទាប់ពីគាត់ចូលប្រឡូកក្នុងកម្មវិធីនេះ ។ វាជំរុញឲ្យគាត់ចេះស្រាវជ្រាវរកឯកសារខ្មែរក្រហមនិងការបោះពុម្ពជាច្រើនអំពីរបបនោះនៅគ្រប់ទីកន្លែងដែលគាត់ទៅដល់ ។ នៅពេលមួយ តហៀវ បានប្រទះឃើញទស្សនាវដ្ដីស្វែងរកការពិតចំនួន២-៣ច្បាប់នៅក្នុងស៊ូវ៉ាវ(កន្លែងថ្វាយបង្គំនិងពិធីបុណ្យទ្រង់ទ្រាយតូច) ហើយបានយកទស្សនាវដ្ដីនោះមកអាន ។ អត្ថបទទស្សនាវដ្ដីនោះហាក់ដូចជាស៊ីគ្នាជាមួយសាច់រឿងរបស់ឪពុកម្ដាយគាត់ និងសំណេរដែលគាត់សរសេរ ។ តហៀវ តែងតែស្នើសុំឯកសារអានជាបន្តបន្ទាប់ដើម្បីបង្កើនចំណេះដឹង ។ តហៀវ និយាយថា "ខ្ញុំចង់អានឯកសារបន្ថែមទៀត ពីព្រោះវាសំខាន់ក្នុងការដឹងថា ហេតុអ្វីបានជាពួកគេ (ខ្មែរក្រហម) សម្លាប់មនុស្ស ? " តាមរយៈការសន្ទនារវាងឪពុកម្ដាយនិងកូនបរិយាកាសរៀនសូត្រត្រូវបានបង្កើតឡើងនៅផ្ទះ ។

ប្រវត្តិសាស្ត្រតាមរយៈការសួរនាំក្លាយជាយន្តការមួយដែលជួយផ្សារភ្ជាប់ជំនាន់មួយទៅជំនាន់មួយទៀត ដែលនោះត្រូវបានហៅថា ការសន្ទនារវាងអន្តរជំនាន់ (ជំនាន់មួយទៅមួយទៀត) ហើយការណ៍នេះផ្ដល់ផលប្រយោជន៍ដ៏សំខាន់ដល់សង្គមកម្ពុជានាពេលបច្ចុប្បន្ន ។

កម្មវិធីនេះជួបប្រទះបញ្ហាប្រឈមជាច្រើន ចាប់តាំងពីដើមដំបូងរហូតទីបញ្ចប់ ដោយសារនេះគឺជាកម្មវិធីថ្មី ។ បញ្ហាប្រឈមជាច្រើនមកពីពេលវេលានិងវិធីសាស្ត្ររបស់យុវជនក្នុងការសម្ភាសឪពុកម្ដាយ និងការសម្រេចចិត្តរបស់គណៈកម្មការត្រួតពិនិត្យក្នុងការជ្រើសរើសសំណេរទាំង១០ ។

ប៉ុន្តែយើងបានជម្នះ បញ្ហាទាំងនេះតាមរយៈការខបត្តម្ភនិងឆ្លើយសំណួរផ្សេងៗរបស់យុវជន ។ ក្រុមការងារនៅតែជំរុញឲ្យយុវជន បន្តសរសេរដោយមិនឲ្យបោះបង់ការខិតខំប្រឹងប្រែងចោលឡើយ បើទោះបីជា មានការលំបាកក៏ដោយ ។ យើងបានស្នើឲ្យយុវជនធ្វើការស្តាប់និងកត់ត្រាការសន្ទនាជាមួយឪពុកម្តាយ តាមរយៈមធ្យោបាយផ្សេងៗបុទៅសួរសុខទុក្ខពួកគាត់ក្នុងអំឡុងពេលវិសម្សកាល ។ យើងក៏បានបន្ថែម ពេលវេលាឲ្យយុវជន ដើម្បីធ្វើឲ្យឪពុកម្តាយនិយាយជាមួយកូនៗរបស់គាត់ និងទុកពេលឲ្យយុវជនសរសេរ ។ នៅក្នុងការវាយតម្លៃសាច់រឿងរបស់យុវជន យើងបញ្ចូលផ្នែកសំខាន់ៗនិងទទួលស្គាល់ការខិតខំប្រឹងប្រែងរបស់យុវជន ។ ប៉ុន្តែ ដើម្បីជំរុញការសរសេរឲ្យ ប្រសើរឡើងយើងបានជ្រើសរើស សំណេរដែលល្អជាងគេ១០ធ្វើជាគំរូ ។ យើងនឹងបន្តកម្មវិធីនេះនៅឆ្នាំ ២០១១ ទៀត ។

## ការប្រមូលវត្ថុបុរាណនិងការថែរក្សាវប្បធម៌

វិធីមួយទៀតដែលជំរុញការចងចាំរបស់សហគមន៍គឺតាមរយៈការថែរក្សាវប្បធ៌ម និងឧបករណ៍រំឭក ។ គម្រោងប្រវត្តិសាស្ត្រតាមរយៈការសួរនាំបានចាប់ផ្តើមប្រមូលឧបករណ៍និង សម្ភារៈមួយចំនួនដែលហៅថាវត្ថុបុរាណពីសហគមន៍ចាមតាំងពីឆ្នាំ២០០៥ ។ ការប្រមូលនេះគឺមានសារសំខាន់សម្រាប់ហេតុផលមួយចំនួន ។ ទី១ ដើម្បីស្វែងរកការពិត ទី២ ជួយដាស់ការចងចាំរបស់ មនុស្សក្នុងការនិយាយប្រាប់សាច់រឿង ទាក់ទងនឹងឧបករណ៍ទាំងនោះ និងទី៣ ជួយអប់រំក្មេងជំនាន់ក្រោយអំពីរបបខ្មែរក្រហមតាមរយៈការដាក់តាំង បង្ហាញរបស់ដែលប្រមូលបាន ។ ជាគោលការណ៍ វត្ថុមួយមានសាច់រឿងមួយ ហើយដែលជួយមនុស្សឲ្យ លាតត្រដាងសាច់រឿងនិងព័ត៌មានបន្ថែមទៀត ។

ក្រុមការងារប្រមូលបានចានបាយ២ ដាវ២ ថាស១ សៀវភៅសាសនាអ៊ីស្លាមចាស់១ និងរូបថតចាស់ៗជាច្រើន ហើយនឹងបន្តប្រមូលថែមទៀត ។ ដាវដែលប្រមូលបានត្រូវបានប្រើប្រាស់សម្រាប់ការ តាំងពិព័រណ៍នៅប្រទេសស៊ុយអែត ហើយសាច់រឿងរបស់អ្នករស់រានមានជីវិតម្នាក់ត្រូវបានដាក់តាំងនៅប្រទេសស៊ុយអែតក្នុងឆ្នាំ២០០៦ ។ ជាបន្ថែមទៅនឹងឧបករណ៍ដែលប្រមូលបានរវាងឆ្នាំ២០០៤ និង ២០០៨ ក្រុមការងារក៏បានប្រមូលសាច់រឿងប្រហែល១០០ច្បាប់ពីជនជាតិចាមដែលរស់រានមានជីវិតពីរបបខ្មែរក្រហម ។ សាច់រឿងទាំងនោះនិយាយពីបទពិសោធន៍ក្នុងអំឡុងរបបខ្មែរក្រហម និងគេរដំណែលពីរបបនោះ ។

បន្ថែមលើសពីនេះទៅទៀត ការអប់រំនិងការថែរក្សាវប្បធម៌ដែលជាផ្នែកមួយរបស់គម្រោងប្រវត្តិសាស្ត្រតាមរយៈការសួរនាំស្ទុះស្ទែងថែរក្សាអគារចាស់ៗ និងសំណល់ស្ថាបត្យកម្មទាំងឡាយ នៅក្នុងសហគមន៍ចាម រួមមានវិហារសាសនា ស៊ូរ៉ាវ សាលាបង្រៀនសាសនា ផ្លូវ អតីតរោង បាយខ្មែរក្រហម ។ល ។ ថ្មីៗនេះ ក្រុមការងារបានជ្រើសរើសសហគមន៍ចាមចំនួន២ធ្វើជាគំរូសម្រាប់សហគមន៍ចាមផ្សេងទៀតនៅកម្ពុជាដើម្បី ជំរុញការអប់រំ វប្បធម៌ ប្រវត្តិសាស្ត្រ នៅក្នុងសហគមន៍ក្នុងគោលបំណងបង្កើនការយល់ដឹងទៅលើរបប ខ្មែរក្រហមនិងប្រធានបទផ្សេងទៀត ។ គម្រោងនេះកំពុងតែរៀបចំនិងអនុវត្តនៅដើមឆ្នាំក្រោយ ។

## ២. ប្រវត្តិសាស្ត្រតាមរយៈការសួរនាំជាបែបផែនសិល្បៈនិងការបកស្រាយ

### ក. ចរិតលក្ខណៈបទសម្ភាសន៍

បទសម្ភាសន៍មិនគ្រាន់តែជាសាច់រឿងឬខ្សែជីវិតរបស់អ្នករៀបរាប់ទេ ថែមទាំងបង្កប់នូវសិល្បៈនៃការ និយាយដែលអ្នករៀបរាប់ធ្វើឡើង ។ ដូចជា ផតថែលលី បានអះអាង ប្រវត្តិសាស្ត្រតាមរយៈការសួរនាំគឺជាបែបផែនសិល្បៈឬក៏ថាបែបផែនសិល្បៈមាននៅក្នុង ប្រវត្តិសាស្ត្រតាមរយៈការសួរនាំ ដោយសារអ្នក និយាយរៀបរាប់បង្ហាញពីសាច់រឿងរបស់ខ្លួន ដោយប្រើប្រាស់ភាសាជាក់លាក់ណាមួយ ប៉ុន្តែជួនកាល ក៏ប្រើភាសាលាយគ្នា ការបញ្ចេញសំឡេង និងល្បឿននៃការនិយាយ ។ អ្នករាយរ៉ាប់មួយចំនួន និយាយជាភាសាខ្មែរលាយចាម ហើយអ្នកខ្លះទៀតក៏និយាយលាយភាសាជ្វា ។ នៅពេលដែលលំបាក បង្ហាញចេញនូវការរំជើប រំជួលអារម្មណ៍ក្នុងបទសម្ភាសន៍ ស្ត្រីចាមម្នាក់នៅខេត្តពោធិសាត់និយាយ ភាសាចាម ដើម្បីពិពណ៌នាផ្នែកនោះ ដែលនេះឆ្លុះបញ្ចាំងពីអត្តសញ្ញាណរបស់គាត់ ។

អ្នកផ្តល់បទសម្ភាសន៍មួយចំនួននិយាយសាច់រឿងប្រកបដែលវោហារសព្ទដែលទាក់ទាញ ។ អ្នកផ្សេងទៀតដែលនិយាយពីសាច់រឿងក្រៀមក្រំរហូតដល់យំ ។ អ្នកខ្លះទៀតសួរបញ្ជាក់អ្នកធ្វើបទសម្ភាសន៍ថា តើការរៀបរាប់របស់គាត់អាចទទួលយកជាការបានដែរឬអត់? ខ្ញុំនៅចាំបានថា ស្ត្រីម្នាក់បានសួរខ្ញុំនៅពេលចាប់ ផ្តើមសម្ភាសន៍ ថាតើល្បឿននិយាយរបស់គាត់សមល្មម ហើយសំឡេងរបស់គាត់អាចទទួលយកបានដែរឬអត់ ។ សញ្ញាណនេះបញ្ជាក់ពីសិល្បៈនៃការរៀបរាប់សាច់រឿងដែលអ្នកផ្តល់សម្ភាសចូលចិត្ត ។

បន្ថែមទៅនឹងការលើកឡើងខាងលើ ស្រទាប់នៃការចងចាំក៏ត្រូវបានចាត់ទុកថាជាផ្នែកមួយនៃបែបផែនសិល្បៈ (ហ្សូនរ៉ឺ) ។ នេះសំដៅទៅដល់ការចងចាំនូវហេតុការណ៍ជាច្រើននៅពេលដែលវេលា

កន្លងទៅ ។ ដូចបានបញ្ជាក់ពីខាងដើម ការចងចាំ គឺសំខាន់សម្រាប់មនុស្សក្នុងការរំឭកឡើងវិញនូវរឿងរ៉ាវរបស់ខ្លួន ។ គួរឲ្យកត់សម្គាល់ ការចងចាំទៅលើរបបខ្មែរក្រហមទទួលឥទ្ធិពលដល់ការចងចាំទៅលើហេតុការណ៍បន្តបន្ទាប់ ដោយតាមរយៈនេះ វាប៉ះពាល់ដល់អ្វីដែលមនុស្សរំឭករឿងរ៉ាវរបស់ខ្លួន ។ ការចងចាំរបស់មនុស្សត្រូវបានបង្កើតឡើងហើយបង្កើតទៀតនៅពេលវេលាកន្លងផុតទៅ ហើយឆ្លងកាត់ការបំលែង យ៉ាងច្រើនដូច្នេះដែរ ។ ទោះបីយ៉ាងណាក៏ដោយ នេះមិនមែនជារឿងចម្លែកសម្រាប់មនុស្សដែលរស់នៅសង្គមមួយទៅសង្គមមួយទៀតឡើយ ។ ហើយសំណួរថាតើមនុស្សមានការចងចាំតែពីរបបខ្មែរក្រហមសុទ្ធ ដែរឬអត់គឺជារឿងមិនសូវសំខាន់ ។ អ្នកផ្តល់សម្ភាសន៍ភាគច្រើនមានការចងចាំប្រភេទនេះ ហើយរៀបរាប់ សាច់រឿងរបស់ខ្លួន ដោយផ្សារភ្ជាប់ជាមួយហេតុការណ៍បន្តបន្ទាប់ទៀត ។ ទោះបីជាយ៉ាងណា ការចងចាំ ហេតុការណ៍រន្ធត់ខ្លាំង ដូចជារបបខ្មែរក្រហម ត្រូវបានចងចាំយ៉ាងខ្លាំង ហើយកប់ក្នុងចិត្តរបស់មនុស្ស ប៉ុន្តែជួនកាលមានការលំបាកក្នុងការនិយាយចេញ ដោយសារតែវានាំមកជាមួយនូវការឈឺចាប់ ។ ហើយការណ៍នេះ ទាមទារពេលវេលានិងការលើកទឹកចិត្តដើម្បីជួយឲ្យគាត់និយាយចេញមក ។

### ១. ការបកស្រាយ

ជាបន្ថែម ការសម្ភាសមានគោលបំណងបកស្រាយយ៉ាងទូលំទូលាយឬរួមផ្សំដោយធាតុបកស្រាយ ។ ការបកស្រាយបង្កប់នូវអត្ថន័យ ដែលរួមមានហេតុការណ៍និងទស្សនៈអំពីអ្វីដែលបានកើតឡើង និងថាតើហេតុការណ៍ប៉ះពាល់ដល់ជីវិតមនុស្សបែបណា ។ ក្នុងន័យម្យ៉ាងទៀត អ្នកស្រាវជ្រាវជាន់ខ្ពស់មើល ឃើញលក្ខណៈនេះថា ជាកិច្ចខិតខំប្រឹងប្រែងរបស់អ្នកផ្តល់បទសម្ភាសន៍ ក្នុងការធ្វើឲ្យសាច់រឿងរបស់គាត់សមហេតុសមផល ។ អ្នកប្រវត្តិសាស្ត្រតាមការសួរនាំឲ្យហេតុផលថា តាមរយៈបទសម្ភាសន៍ សមាជិក សហគមន៍បង្កប់នូវបទពិសោធន៍របស់ខ្លួនទៅក្នុងកំណត់ត្រាប្រវត្តិសាស្ត្រ ហើយផ្តល់ការបកស្រាយទៅលើ ប្រវត្តិសាស្ត្រនិងបទពិសោធន៍របស់ខ្លួន ។

វាមានសារសំខាន់ក្នុងការក្រឡេកមើលថាតើអ្នកសម្ភាសយល់ដឹងប៉ុនណាទៅលើសាច់រឿងរបស់អ្នកផ្តល់បទបទសម្ភាសន៍ ។ លក្ខណៈដែលអ្នកផ្តល់បទសម្ភាសន៍យល់ដឹងនិងវិភាកសាច់រឿងរបស់អ្នកផ្តល់បទសម្ភាសន៍ អាស្រ័យទៅលើសាច់រឿងផ្ទាល់និងការអន្តេត ។ ជាដំបូង គឺការយល់ដឹងពាក្យតាមតំបន់និងបន្ទាប់មកការយល់ពីសកម្មភាពដែលបង្ហាញឡើងក្នុងកិច្ចសម្ភាសន៍ ។ គួរឲ្យកត់សម្គាល់ថា អ្នកផ្តល់បទសម្ភាសន៍ព្យាយាមផ្សារភ្ជាប់សាច់រឿងរបស់ខ្លួនជាមួយអ្នកដទៃ ។ នេះមានន័យថា ពួកគេមិនមែន

និយាយតែពីខ្លួនឯងទេ ប៉ុន្តែថែមទាំងអ្នកដទៃទៀតផងដែរ គឺពីអ្វីដែលពួកគាត់ឃើញ និងដឹងអំពីអ្នកដទៃនៅក្នុងហេតុការណ៍តែមួយ ។ ជាធម្មតា ស្ត្រីចាមក៏លើកឡើងពីអ្នកដទៃប៉ុន្តែសង្កត់ធ្ងន់លើបទពិសោធន៍ផ្ទាល់ខ្លួនយ៉ាងខ្លាំង ។ អ្នកផ្តល់បទសម្ភាសន៍តែងតែរៀបរាប់ពី ថាតើហេតុការណ៍នោះប៉ះពាល់ដល់ពួកគាត់យ៉ាងម៉េច ជាជាងថា តើហេតុអ្វីបានជាហេតុការណ៍នោះបានកើតឡើង ។ ដូច្នេះការរៀបរាប់ បង្កប់នូវវិធីសាស្ត្រការចងចាំទៅលើ ហេតុការណ៍ជាច្រើន ប៉ុន្តែអ្វីដែលអ្នកផ្តល់បទសម្ភាសន៍ចងចាំបំផុតគឺរបបខ្មែរក្រហមនិងការបកស្រាយ របស់អ្នកផ្តល់បទសម្ភាសន៍ ។ ដូច្នេះ ការរៀបរាបជាបណ្តុំសិល្បៈនៃការនិយាយវត្ថុដែលអាចជួយជាស់ការចងចាំនិងវិធីសាស្ត្ររបស់អ្នកធ្វើបទសម្ភាសន៍ព្រមទាំងការបកស្រាយរបស់អ្នកផ្តល់បទសម្ភាសន៍ ។

## ២. ដំណើរការស្វែងរកការពិតឬគណៈកម្មការស្វែងរកការពិត ហេតុអ្វីបានជានិយាយប្រាប់រឿងរ៉ាវមានសារសំខាន់? តើការរំឭកពីការឈឺចាប់អាច ធ្វើឲ្យឈឺចាប់សាជាថ្មីឬទេ?

ខណៈដែលចម្លើយទៅនឹងសំណួរទី១គឺ “មានសារសំខាន់” សម្រាប់សំណួរទី២នៅតែអាចធ្វើការពិភាក្សា ។ ជាទូទៅ អ្នករស់រានមានជីវិតជាពិសេសជនរងគ្រោះនៃសោកនាកម្ម ត្រូវបានលើកទឹកចិត្តឲ្យនិយាយប្រាប់នូវបទពិសោធន៍ផ្ទាល់ខ្លួននិងទាមទាររកការពិតដូចអ្វីដែលពួកគាត់ធ្លាប់ឃើញថាតើពួកគេ ឆ្លើយទៅនឹងព្រឹត្តិការណ៍នោះយ៉ាងដូចម្តេច ហើយព្រឹត្តិការណ៍នោះប៉ះពាល់យ៉ាងដូចម្តេចដល់ពួកគេ ។ អ្នកប្រវត្តិវិទូជាច្រើនបានទទួលស្គាល់ថា ការរំឭករឿងទុក្ខសោកគឺនាំឲ្យមានការឈឺចាប់ និងមានអារម្មណ៍រំជើបរំជួលខ្លះ ប៉ុន្តែក៏ធ្វើឲ្យអ្នកនិយាយនោះមានការធូរស្បើយមួយកម្រិតដែរ ។ មានអ្នកផ្តល់បទសម្ភាសន៍ ជាច្រើនបង្ហូរទឹកភ្នែកនិងយំខ្សឹកខ្សួលខណៈពេលកំពុងរៀបរាប់រឿងរ៉ាវរំជួលចិត្តរបស់ពួកគេ ប៉ុន្តែនៅពេល ដែលពួកគេផ្តល់បទសម្ភាសន៍ភ្លាម និងបន្តបន្ទាប់មកទៀត ពួកគេនឹងមានអារម្មណ៍ធូរស្រាលខ្លះ ។ ឧទាហរណ៍ សុះ ភះ ជាអ្នកគ្រូបង្រៀនសាសនាអ៊ីស្លាមនៅខេត្តកំពង់ធំបាននិយាយថា គាត់ជាទូទៅអាចរកឃើញភាពធូរស្បើយតាមរយៈការរាយរ៉ាប់រឿងរ៉ាវរបស់គាត់ ដែលនៅពេលរៀបរាប់គាត់ក៏បានបង្ហូរទឹកភ្នែកដែរ ។ ប៉ុន្តែរឿងទាំងនេះកើតឡើងលុះត្រាតែមានអ្នកស្តាប់ដែលប្រកបដោយភាពអាណិតអាសូរ និងយកចិត្តទុកដាក់ស្តាប់ព្រមទាំងទទួលស្គាល់នូវការឈឺចាប់របស់គាត់ ។ ការមិនយកចិត្តទុកដាក់ស្តាប់ និងមិនចេះ បត់បែនទៅតាមអត្តចរិតរបស់អ្នកផ្តល់បទសម្ភាសន៍គឺមានន័យថា អាចប៉ះពាល់ដល់អ្នកផ្តល់បទសម្ភាសន៍ ។ អ្នកផ្តល់បទសម្ភាសន៍អាចមានអារម្មណ៍ថា ខ្លួនឯងខុស និងភ័យខ្លាចថា អ្វីដែលគាត់និយាយត្រូវគេបដិសេធ ។ ទីម៉ាស់ នៅខេត្តកណ្តាលបាន

បញ្ជាក់ថា អ្វីដែលគាត់និយាយជាការពិតព្រោះគាត់បានបាត់បង់ប្អូនប្រុសនៅគុកទួលស្លែងក្នុងសម័យខ្មែរក្រហម ។ គាត់ចង់ឲ្យអ្នកស្តាប់ធ្វើជាសាក្សីក្នុងរឿងរ៉ាវរបស់គាត់ការបាត់បង់ប្អូន ប្រុសរបស់គាត់ព្រមទាំងការរងទុក្ខរបស់គាត់ផ្ទាល់ ។ ទោះជាយ៉ាងណាក្តី គាត់ហាក់ដូចជាមិនចង់ព្រួយបារម្ភនូវការមិនជឿជាក់ពីអ្នកដែលកំពុងស្តាប់គាត់នោះទេ ។ ជាមួយគ្នានេះដែរ ស្ត្រីខ្មែរក្រោមម្នាក់ដែលបានបាត់បង់សមាជិកគ្រួសារចំនួន១៩នាក់នៅក្នុងសម័យខ្មែរក្រហមបានរំឮករឿងរបស់គាត់ដោយអារម្មណ៍ឈឺចាប់ ។ ទោះបីជាគាត់មានអារម្មណ៍មិនសូវស្រួលនៅពេលដែលគាត់លាតត្រដាងការពិតគាត់ក៏ដោយ ក៏គាត់នៅតែខិតខំរៀបរាប់បន្តទៅទៀតទាំងអួលដើមកដើម្បីអប់រំក្មេងជំនាន់ក្រោយពីប្រព្រឹត្តការណ៍ដែលបានកើតឡើង ។

ប៉ុន្តែអ្វីនឹងកើតឡើងប្រសិនបើជនរងគ្រោះមិននិយាយអ្វីទាល់តែសោះ? នៅក្នុងសម័យខ្មែរក្រហមសេរីភាពនៃការនិយាយស្តីត្រូវបានហាមឃាត់ ។ ប្រជាជនមិនត្រូវបានគេអនុញ្ញាតឲ្យបញ្ចេញឬអារម្មណ៍ពិតរបស់ខ្លួន ។ ពួកគាត់បានក្លាយជាជនរងគ្រោះក្រោមនយោបាយនេះ ដែលមិនអាចធ្វើជាម្ចាស់លើវាសនារបស់ខ្លួន ។ ដូច្នេះការនិយាយចេញមកអាចធ្វើឲ្យគាត់យកឈ្នះនូវអ្វីដែលខ្មែរក្រហមបានហាមឃាត់គាត់ ។ សំខាន់ដូចគ្នានេះដែរ នេះគឺជាការកត់ត្រានូវបទពិសោធន៍របស់ពួកគាត់សម្រាប់គោលបំណងអប់រំអំពីរបបខ្មែរក្រហម ។

ដូចដែលបញ្ជាក់ពីខាងដើមប្រវត្តិសាស្ត្រតាមការសួរនាំដើរតួនាទីជាច្រើន ។ នៅក្នុងគម្រោងជាក់លាក់មួយចំនួនតួនាទីមួយសំខាន់បំផុតគឺដំណើរការស្វែងរកការពិតតាមរយៈប្រមែប្រមូលសក្ខីកម្មពីជនរងគ្រោះនិងជនដៃដល់ជាច្រើននាក់ ។ ឧទាហរណ៍ នៅក្នុងគណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សានៅប្រទេសអាហ្វ្រិចខាងត្បូង ការធ្វើសក្ខីកម្មផ្ទាល់មាត់ត្រូវបានគេប្រមូលទុកធ្វើជាភ័ស្តុតាងនៅក្នុងដំណើរការទាំងមូល ។ ដោយបង្ហាញនូវការពិតយ៉ាងទូលំទូលាយនោះ នឹងអាចជួយឲ្យមានការជាសះស្បើយខាងផ្លូវចិត្ត ។ ក្នុងនាម ជាប្រវត្តិវិទូតាមរយៈការសួរនាំមិនអាចផ្តោចតែទៅលើឯកសារផ្លូវការឬក៏ប្រវត្តិសាស្ត្រដែលគេដឹងជាទូទៅ តែមួយមុខទេ ដើម្បីស្វែងយល់ពីបទពិសោធន៍ទាំងមូល ។ ជាមួយគ្នានេះប្រវត្តិសាស្ត្រតាមរយៈការសួរនាំគឺជាផ្នែកមួយយ៉ាងក្នុងការប្រមូលរឿងរ៉ាវប្រវត្តិសាស្ត្រផ្ទាល់មាត់របស់ប្រទេសមួយដែលទទួលរងការបំផ្លិច បំផ្លាញផ្នែកសង្គម នយោបាយ សាសនា សេដ្ឋកិច្ច វប្បធម៌ និងការអប់រំ ព្រមទាំងជួយ កសាងប្រទេសជាតិឡើងវិញ ។ ដូច្នេះវាដើរតួនាទីសំខាន់ក្នុងការកត់ត្រាការរំលោភសិទ្ធិមនុស្សនៅក្នុងរបប ពិសេសមួយដូចជាខ្មែរក្រហមជាដើម ។

គម្រោងនេះក៏បានជួយសម្រួលជនរងគ្រោះជាជនជាតិចាមដាក់ពាក្យបណ្តឹងទៅអង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ សក្ខីកម្មផ្ទាល់មាត់និងពាក្យបណ្តឹងរបស់ពួក

គាត់ត្រូវបានបញ្ជូនទៅអង្គជំនុំជម្រះទាំងក្នុងសំណុំរឿងលេខ០០១និងលេខ០០២ ។ ដូចនេះ ការអនុញ្ញាតឲ្យប្រជាជន ព្រមទាំងជនជាតិភាគតិចជាច្រើននិយាយ និងបង្ហាញពីមតិរបស់ពួកគាត់ពីរបបរំលោភបំពាននេះគឺជាមូលដ្ឋាន គ្រឹះមួយនៃការគោរពសិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យ ។

សរុបមក ក្រៅពីឧបសគ្គខ្លះៗ ប្រវត្តិសាស្ត្រតាមរយៈការសួរនាំគឺជាដំណើរមួយផ្ដោះទៅរកគណៈកម្មការស្វែងរកការពិត និងគម្រោងប្រមូលឯកសារដើម្បីស្វែងរកការពិតពីប្រជាពលរដ្ឋដែលមានឋានៈតូចទាប និងដែលសំឡេងរបស់គាត់មិនសូវបានដឹងឮ ។ នេះជាវិធីមួយក្នុងការរក្សានូវភាពចងចាំនិង ការជាសះស្បើយមួយកម្រិត ។

## ក. ប្រវត្តិសាស្ត្រតាមរយៈការសួរនាំនិងការជាសះស្បើយក្រោយពីអំពើហិង្សា

បើពិនិត្យទៅលើកេរដំណែលពីអតីតកាលនៅក្នុងគ្រួសារនិងសង្គម ប្រវត្តិសាស្ត្រតាមរយៈការសួរនាំធ្វើឲ្យមានការយល់ដឹងយ៉ាងទូលំទូលាយពីតម្រូវការយុត្តិធម៌អន្តរកាល ដើម្បីទទួលស្គាល់នូវការឈឺចាប់របស់ជនរងគ្រោះបង្កើតឲ្យមានីតិរដ្ឋនិងសន្តិភាពនៅក្នុងសហគមន៍ ។ យុត្តិធម៌អន្តរការសំដៅទៅលើ "ការឆ្លើយតបទៅនឹងនយោបាយមានលក្ខណៈជាប្រព័ន្ធ និងការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ" ដែលមានគោលបំណង ដោះស្រាយបញ្ហាអតីតកាល ដោយនាំមកនូវលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្សនិង សំណងដល់ជនរងគ្រោះ ។ ការវិភាគនូវបទពិសោធន៍ ដែលក្រុមជនជាតិភាគតិចឆ្លងកាត់របបខ្មែរក្រហមរួមចំណែកក្នុងការស្វែងរកការពិតទូលំទូលាយ ។ នេះអាចឲ្យយើងរកយុត្តិធម៌សមរម្យមួយសម្រាប់ប្រជាជនទូទៅ ។

បើយើងសួរថាតើយុត្តិធម៌ប្រភេទណាដែលជនជាតិចាមត្រូវការ នោះគឺទាំងយុត្តិធម៌ផ្លូវច្បាប់ឬតុលាការ និងយុត្តិធម៌តាមមិនតាមផ្លូវច្បាប់ គឺសង្កត់ធ្ងន់ទៅលើសំណងដើម្បីសងអ្វីដែលពួកគាត់បានបាត់បង់ ។ ពួកគាត់ឲ្យយោបល់ថា ជាការសមហេតុផលណាស់ដែលមេដឹកនាំខ្មែរក្រហម ត្រូវបានកាត់ ទោសពីព្រោះទង្វើនេះសមស្របទៅតាមច្បាប់សាសនាអ៊ីស្លាម ។ នៅក្នុងសាសនាអ៊ីស្លាមហាលីម៉ាស់បានបញ្ជាក់ថា "អ្នកដែលប្រព្រឹត្តអំពើល្អនឹងទទួលផលល្អ ហើយអ្នកប្រព្រឹត្តអំពើអាក្រក់នឹងទទួលផលអាក្រក់" ។ ខ្ញុំបានកត់សម្គាល់ថាទ្រឹស្ដីនេះត្រូវគ្នាជាមួយទ្រឹស្ដីកម្មផលរបស់សាសនាព្រះពុទ្ធដែរ ។

ទាក់ទងនឹងសំណង គ្មាននរណាម្នាក់លើកឡើងពីសំណងផ្នែកហិរញ្ញវត្ថុទេ ។ ពួកគាត់ចង់ឲ្យមានការជួសជុលព្រះវិហារអ៊ីស្លាមឬក៏សាងសង់សាលារៀនខាងសាសនា នៅក្នុងសហគមន៍របស់ពួកគាត់គ្លីនិកសេវាកម្មសុខភាព និងការពិនិត្យព្យាបាលសុខភាពដោយមិនគិតថ្លៃ ។ ពួកគាត់ទទួលស្គាល់ថា អ្វីទាំងនេះ

មិនអាចជួយឲ្យអ្នកជាទីស្រឡាញ់របស់គាត់រស់ឡើងវិញបុ៉ន្តែមិនអាចប្រៀបទៅនឹងអ្វីដែលគាត់បាត់បង់ទេ បុ៉ន្តែពួកគាត់និយាយថាយ៉ាងហោចណាស់ទាំងនេះអាចធ្វើឲ្យពួកគេមានអារម្មណ៍ធូរស្រាលជាងមុនដែរ ។

បន្ថែមលើសពីនេះ ពួកគេក៏បានបញ្ជាក់ថា ការសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមនិងការរក្សាការចងចាំ គឺសុទ្ធតែមានសារសំខាន់ខ្លាំងណាស់ ។ ជាមួយគ្នានេះដែរ មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានសហការជាមួយក្រសួងអប់រំយុវជននិងកីឡាកំពុងតែធ្វើការងារដើម្បីបំពេញលើចំណុចនេះ ។

នៅពេលដែលអ្វីទាំងនេះក្លាយជាការអប់រំអំពីអំពើប្រល័យពូជសាសន៍ផ្លូវការមួយគម្រោងប្រវត្តិសាស្ត្រតាមរយៈការសួរនាំនឹងក្លាយជាផ្នែកមួយនៃការអប់រំប្រវត្តិសាស្ត្រខ្មែរក្រហមបែបមិនផ្លូវការ ។ គម្រោងនេះនឹងក្លាយជាគ្រឹះដ៏មាំសម្រាប់រក្សានូវរឿងរ៉ាវរបស់អ្នករស់រានមានជីវិតជនជាតិចាមជាច្រើន ។

ការកត់ត្រាពីបទពិសោធន៍របស់ជនជាតិចាមដែលឆ្លងកាត់របបខ្មែរក្រហមគឺមានសារសំខាន់ខ្លាំងណាស់សម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីគាំទ្រនូវការចោទប្រកាន់មេដឹកនាំខ្មែរក្រហមពីបទប្រល័យពូជសាសន៍ ។ លើសពីនេះ នៅពេលដែលភ័ស្តុតាងជាលាយលក្ខណ៍អក្សរនៅមានកម្រិតនោះ ប្រវត្តិសាស្ត្រតាមរយៈការសួរនាំអាចបម្រើជាភ័ស្តុតាងសំខាន់ដើម្បីបន្ថែមទម្ងន់ទៅលើឯកសារនៅក្នុងនីតិវិធីច្បាប់ ។

### ៤. លទ្ធផល បទពិសោធន៍ និង ការប្រឈមនានា

ការធ្វើការជាមួយអ្នករស់រានមានជីវិតពីរបបប្រល័យពូជសាសន៍ ខ្ញុំភ្ញាក់ផ្អើលដោយឃើញសេចក្តីក្លាហានក្នុងការប្រឈមមុខនឹងអតីតកាលរបស់អ្នកផ្តល់សម្ភាសន៍ជាច្រើន ។ ពួកគាត់ខិតខំព្យាយាមចេញឲ្យផុតពីជនរងគ្រោះទៅជាអ្នករស់រានមានជីវិតហើយដើរតួនាទីជាអ្នកថែរក្សាកូនៗរបស់គាត់ទៀតផង ។ ពួកគេជឿជាក់ថា ការអប់រំកូនចៅតាមរយៈការរៀបរាប់រឿងរ៉ាវ របស់គាត់ជាវិធីសាស្ត្រដ៏ល្អក្នុងការបង្រៀនកូនចៅពីរបបកម្ពុជាប្រជាធិបតេយ្យ ។ ខ្ញុំក៏បានសង្កេតផងដែរថាក្មេងជំនាន់ក្រោយ មានការស្វះស្វែងក្នុងការចង់ចេះ ចង់ដឹងអំពីរបបខ្មែរក្រហមនិងថាតើឪពុកម្តាយពួកគេអាចរួចរស់ជីវិតយ៉ាងដោយរបៀបណា ។ មានយុវជនខ្លះបានកែប្រែឥរិយាបថមិនសមរម្យទៅជាអ្នកដឹងគុណឪពុកម្តាយរបស់ខ្លួនវិញ ។ ណាសៀតសារភាពថាគាត់នឹងប្តេជ្ញាចិត្តធ្វើជាកូនដ៏ល្អដោយមិនធ្វើឲ្យឪពុកម្តាយរបស់គាត់ព្រួយបារម្ភពីគាត់ទៀតឡើយ ។ ការប្រឹងប្រែងនៅក្នុងការជួបជុំនៅក្នុងសហគមន៍និងការប្រមូលនូវការ ចងចាំគឺជាសញ្ញាវិកចម្រើននិងការចងចាំ ។

សមាជិកសហគមន៍គាំទ្រគម្រោងនេះ ហើយពួកគាត់បានផ្ញើប្រតិកម្មរបស់ពួកគាត់និងសំណូមពរផ្សេងៗមកកាន់ក្រុមការងារ ។ មានគ្រួសារខ្លះផ្ញើសេចក្តីប្រកាសរកបងប្អូនដែលបាត់បង់ក្នុងរបបខ្មែរ

ក្រហមនិងស្នើឲ្យមានការចុះផ្សាយ ក្នុងទស្សនាវដ្តីស្វែងរកការពិតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលចេញផ្សាយប្រចាំខែ ។ ទាំងនេះអាច ជួយឲ្យយើងអាចផ្សារភ្ជាប់ទំនាក់ទំនងសហគមន៍បានប្រសើរ ។ លើសពីនេះសារព័ត៌មានគឺជា មធ្យោបាយមួយក្នុងការផ្តល់ជាសារពីសហគមន៍ចាមនិងត្រូវបានប្រើប្រាស់ក្នុងការវាយតម្លៃគម្រោង ។

យើងដឹងថាការខិតខំប្រឹងប្រែងក្នុងការនាំមកនូវសំឡេងរបស់ស្ត្រីជនជាតិចាមអ្នកដឹកនាំសាសនា យុវជននិងប្រជាជនចាមសាមញ្ញមកក្នុងប្រវត្តិសាស្ត្រទាំងមូលគឺផ្តល់សារសំខាន់និងនាំមកនូវការប្រឈមនានា ។ ចំណុចទីពីរនេះ គឺផ្តោតជាចម្បងទៅលើការចោទសួរអំពីការចងចាំដែលអាចទុកចិត្តបាននិងភាពត្រឹមត្រូវឥតខ្ចោះរបស់ប្រភពឯកសារផ្ទាល់មាត់ ។

ប្រភពព័ត៌មានផ្ទាល់មាត់មានសារប្រយោជន៍ផ្សេងៗគ្នា ។ រាល់ឯកសារសរសេរភាគច្រើន (កំណត់ត្រាអង្គប្រជុំរបាយការណ៍ ។ល ។) គឺសុទ្ធតែផ្អែកលើការនិយាយផ្ទាល់មាត់ទាំងអស់ ប៉ុន្តែភាពសំខាន់ដែលអ្នកប្រវត្តិសាស្ត្រឲ្យតម្លៃគឺហាក់បីដូចជាយោងទៅតាមពេលវេលានៃការកត់ត្រា ។ ប្រវត្តិវិទូតាមការសួរនាំឲ្យតម្លៃព័ត៌មានទៅតាមសារសំខាន់របស់សាច់រឿង និងការផ្តល់អត្ថន័យរបស់អ្នករៀប-រាប់ ។ ផតថែលលី លើក ឡើងថា "សារសំខាន់នៃការធ្វើសក្ខីកម្មផ្ទាល់មាត់ប្រហែលជាមិនឋិតនៅក្នុងការពិតប៉ុន្តែវាករពើការពិត គឺនៅពេលដែលការស្រមើស្រមៃការផ្តល់ជានិមិត្តរូប និងការប៉ងប្រាថ្នាលេចឡើង ។ មិនមាន "កំហុស" នៅក្នុងប្រភពឯកសារផ្ទាល់មាត់ទេ ។ នៅពេលដែលយើងបានពិនិត្យមើលទៅលើភាពសុក្រឹតនៃប្រភពនេះ ដោយផ្ទៀងផ្ទាត់ជាមួយលក្ខន្តិកៈនៃការរិះគន់តាមបែបទស្សនវិជ្ជានិងហេតុការណ៍ពិតដែលតម្រូវចាំបាច់សម្រាប់ប្រភេទនៃប្រភពឯកសារនីមួយៗភាពពិសេសដាច់ដោយឡែកពីគ្នានៃប្រវត្តិសាស្ត្រផ្ទាល់មាត់ទាំងអស់ដែលផ្ទុកទៅដោយការពិតនៅតែត្រឹមត្រូវតាម បែបចិត្តសាស្ត្រ ហើយដែលការពិតនេះប្រហែលជាត្រឹមត្រូវដូចប្រភពឯកសារដើមដែរ" ។

សំឡេងរបស់អ្នកផ្តល់ព័ត៌មានអាចរួមចំណែកចងក្រងប្រវត្តិសាស្ត្រដ៏ពេញលេញមួយ និងការយល់ដឹងពីបទពិសោធន៍របស់មនុស្សព្រមទាំងចងក្រងឡើងវិញនូវអត្តសញ្ញាណខាងជាតិពន្ធុនិងសង្គម ហើយអ្វីទាំងនេះអាចឲ្យអ្នករស់រានមានជីវិតរួបរួមគ្នា ។ ទាំងនេះមានសារសំខាន់ដើម្បីធ្វើឲ្យអ្នកដឹកនាំ សាសនា ជាពិសេស អ្នកដែលមានគំនិតអភិរក្សនិយមយល់ដឹងពីការឈឺចាប់របស់ស្ត្រីនិងសិទ្ធិក្នុងការលាតត្រដាងនូវរឿងផ្ទាល់ខ្លួនរបស់ពួកគេ ។ ទោះជាយ៉ាងណាក្តី មានអ្នកដឹកនាំសាសនាមួយចំនួន នៅតែមានគំនិតមិនសូវបើកទូលាយចំពោះការចូលរួមរបស់ស្ត្រីក្នុងការចូលរួមនៅក្នុងគម្រោងនិងការពិភាក្សាផ្សេងៗ ។ ដូច្នេះចាំបាច់តម្រូវឲ្យមានការព្យាយាមបន្ថែមទៀត

ដើម្បីឲ្យស្ត្រីអាចចូលរួមនៅក្នុងគម្រោង និងរៀបរាប់ពីរឿងរ៉ាវរបស់ពួកគេឲ្យបានទូលំទូលាយ ជាមួយនឹងថ្នាក់ដឹកនាំសហគមន៍ក្មេងជំនាន់ក្រោយនិងប្រជាជនដទៃទៀត ។ ការលើកទឹកចិត្ត និងផ្ដល់ឱកាសឲ្យស្ត្រីនិយាយ និងធ្វើឲ្យគាត់មានជំនឿចិត្តទៅលើការងាររបស់ពួកគេ តាមរយៈការធ្វើបទសម្ភាសន៍ ការពិភាក្សា និងសកម្មភាពផ្សព្វផ្សាយនានា ដើម្បីសម្រេចបាននូវគោលដៅរបស់ខ្លួន ។

ចំណុចមួយទៀតដែលយើងគួរតែធ្វើការកត់សម្គាល់គឺការយល់ដឹងពីវប្បធម៌ ។ ការធ្វើការងារជាមួយក្រុមជនជាតិភាគតិចដូចជាសហគមន៍ចាមដែលកាន់សាសនាអ៊ីស្លាម ការយល់ដឹងពីវប្បធម៌គឺមានសារសំខាន់ណាស់ ។ អ្នកផ្ដល់បទសម្ភាសន៍តែងតែគោរពម៉ោងថ្វាយបង្គំទៀងទាត់ពេលវេលាដូចនេះយើងត្រូវតែទុកពេលវេលាឲ្យគាត់សម្រាប់ធ្វើការប្រណិបត៍ន៍សាសនា ។ បន្ទាប់មកយើងអាចបន្តបទសម្ភាសន៍ទៀត ។ ចំណុចទី២គឺ គឺភាសានិងពាក្យដែលសមាជិក សហគមន៍ប្រើ ។ អ្នកផ្ដល់បទសម្ភាសន៍ តែងតែប្រើភាសានិងពាក្យពេចន៍ដែលពួកគាត់ចូលចិត្ត ។ ដូចនេះអ្នកខាងក្រៅប្រហែលមានការលំបាកក្នុងការចាប់យកភាសា និងពាក្យផ្សេងៗទៀតដែល អ្នកសម្ភាសន៍លើកឡើង ។ ឧទាហរណ៍ "ចៃ" មានន័យថា "សន្តិវង្ស", "ពោធិ" មានន័យថា "ទេវតា ឬទេពធីតា" ណាប៊ី "ព្យាការី" ឬ "ជាអ្នកនាំសារ របស់ព្រះ" ហើយនិង ពាក្យផ្សេងទៀតដែលប្រើនៅតំបន់របស់ពួកគាត់ ។

## សេចក្ដីបញ្ចប់

ប្រវត្តិសាស្ត្រតាមរយៈការសួរផ្ទាល់មាត់មានទាំងចំណុចខ្លាំងនិងកម្រិតរបស់ខ្លួន ។ អ្នកប្រវត្តិ វិទូខ្លះលើកឡើងថា វាមានការប្រថុយប្រថានក្នុងការប្រើប្រាស់ការចងចាំជាប្រភពឯកសារប្រវត្តិសាស្ត្រ ពីព្រោះការចងចាំមិនមែនភាពពេញលេញទេ ។ ទោះជាយ៉ាងណាក្ដី "ការចងចាំ" អាចបំពេញបន្ថែមបាន ។ ពួកគេចោទសួរពីការផ្ដល់ព័ត៌មានផ្ទាល់មាត់ដូចជាការសម្ភាស និងការនិយាយរឿងរ៉ាវ ដោយសង្កត់ធ្ងន់ទៅលើបញ្ហាសុក្រឹតភាពនិងភាពលម្អៀង ។ ពួកគេក៏លើកឡើងផងដែរថា ទំនាក់ទំនងរវាង អ្នកសម្ភាសន៍ និងអ្នកផ្ដល់បទសម្ភាសន៍អាចធ្វើឲ្យមានការប៉ះពាល់ទៅលើអ្វីដែលបានចងចាំ និងការរៀបរាប់ ហើយការបកស្រាយនិងសម្ដែងចេញអាចប៉ះផ្ទាល់ដោយសារភាពលម្អៀងរបស់អ្នកស្រាវជ្រាវនិងអ្នកសម្ភាស ។ លើសពីនេះ ប្រវត្តិសាស្ត្រផ្ទាល់មាត់មិនបានប្រាប់ពីអ្វីដែលបានកើតឡើង និងថាតើព្រឹត្តិការណ៍នោះកើតឡើងយ៉ាងដូចម្ដេចឲ្យបានស៊ីជម្រៅទេ ។ ប៉ុន្តែយើងចាត់ទុកការរិះគន់ខាងលើថា ជាភាពសំខាន់ដាច់ដោយឡែកមួយរបស់ប្រវត្តិសាស្ត្រប្រភេទនេះដែលជួយឲ្យយើងយល់ដឹងពីបទពិសោធន៍របស់មនុស្សនិងវិធីផ្សេងៗ

ដែលមនុស្សប្រើប្រាស់ដើម្បីប្រឈមមុខនឹងការពិត ។ ចន្លោះខ្វះខាតនេះអាចកាត់បន្ថយបានតាមរយៈវិធីសាស្រ្ត និងការអនុវត្តឲ្យបានមត់ចត់នៅពេលយើងចាប់ផ្តើមគម្រោងនេះ ។

ការរៀបរាប់ពីបទពិសោធន៍ក្រោមរបបខ្មែរក្រហមរបស់ជនជាតិចាមមានលក្ខណៈជាបំណែក និងភាពប្រទាក់គ្នាពីចំណុចមួយទៅចំណុចមួយទៀត ។ អ្នកខ្លះមិនអាចរំឭកឡើងវិញនូវហេតុការណ៍ទាំងមូលឬមានការភ្លេចភ្លាំងកាលបរិច្ឆេទនៃហេតុការណ៍ ។ ជួនកាលមិនអាចរៀបរាប់សាច់រឿងតាមលំដាប់លំដោយ ។ ប្រសិនបើពិនិត្យមើលទៅលើអារម្មណ៍រំជើបរំជួលដោយសារ ពួកគាត់ធ្លាប់បានទទួលរង ។ ជនរងគ្រោះមាន ការភ័យខ្លាចថាហេតុការណ៍នោះត្រឡប់មកវិញឬគាត់ត្រូវជួបប្រទះម្តងទៀត ។ ជួនកាល នៅពេលរៀបរាប់ពីការបាត់បង់សមាជិកគ្រួសារ ពួកគាត់មានអារម្មណ៍ថាបានធ្វើខុសដោយសារតែជម្រើសដែលគាត់បានធ្វើដែលនេះមានន័យថា គាត់សួរខ្លួនឯងថា អ្វីដែលគាត់ធ្វើជារឿងត្រឹមត្រូវដែរឬអត់ ។

ទោះជាយ៉ាងក៏ដោយអ្វីដែលគាត់បាននិយាយចេញមកគឺមានសារសំខាន់សម្រាប់ប្រវត្តិ-សាស្រ្ត ដែលនេះជាឧបករណ៍ស្វែង រកការពិត និងយុត្តិធម៌ និងថែរក្សាការចងចាំ ព្រមទាំងដើម្បីអប់រំក្មេងជំនាន់ក្រោយ ។ ដូចដែល អេលីហ្សាប៊ែត តុងគិន បានលើកឡើងថា “ការនិយាយរឿងគឺជាការប្រយុទ្ធប្រឆាំងនឹងការគំរាមកំហែងរបស់ពេលវេលា... ការនិយាយប្រាប់រឿងជួយកុំឲ្យការចងចាំបាត់បង់” ។ សាច់រឿងដ៏មានឥទ្ធិពលទាំងនេះមិនអាចពេញលេញទេហើយវាកើតឡើងហើយកើតឡើងទៀត តាមពេលវេលាដែលកន្លងទៅឬក៏ថា វាត្រូវបាននិយាយហើយនិយាយទៀតនៅក្នុងសហគមន៍ ។ តុងគិន បន្ថែមថា “បច្ចុប្បន្នកាលដែល យើងរស់នៅបានមកពីហេតុការណ៍ពីអតីតកាល” ។ អតីតកាលឆ្លុះបញ្ចាំងតាមរយៈគំនិតនិងអំពើទាំងឡាយ ដែលរបបខ្មែរក្រហមបានបន្សល់ទុកឲ្យ ។ ការចងចាំរបស់អ្នករស់រានមានជីវិតត្រូវបានប៉ះពាល់ម្តងហើយម្តងទៀត ដោយហេតុការណ៍រន្ធត់ ខ្លាំងនិងការបាត់បង់ធំធេង ។ យោងតាម អង់តូនីស រ៉ូបិន ហេតុការណ៍រន្ធត់ខ្លាំង “គឺធំជាងការឈឺចាប់របស់បុគ្គលដោយសារការណ៍នោះធ្វើឲ្យបែកបាក់ទំនាក់ទំនងសង្គមបំផ្លាញអត្តសញ្ញាណរបស់ក្រុមប៉ះពាល់ខ្លាំងដល់ភាពជាសហគមន៍ និងការរង្គោះរង្គើវប្បធម៌នៅពេលអត្ថន័យរបស់វាលែងត្រូវបានប្រើ” ។

ដូចជាមនុស្សដទៃទៀតដែរជនជាតិចាមនៅតែមានសំណួរជាច្រើនអំពីការកាប់សម្លាប់មនុស្សនៅក្នុងរបបនោះ ។ ជនជាតិចាមជាច្រើននៅតែស្វែងរកសមាជិកគ្រួសារដែលបានបាត់ខ្លួន ហើយស្រ្តីចាមមួយចំនួនទៀតកំពុងតែទន្ទឹងរង់ចាំការវិលត្រឡប់មកវិញរបស់កូនៗរបស់គាត់ ។ ខណៈ

ដែលអ្នកខ្លះទៀតនៅតែ សង្ឃឹមថាសមាជិកគ្រួសាររបស់គេនៅរស់នៅឡើយ ។ សារីហ្វាស់ អាយុ ៨៤ឆ្នាំដែលមានទីលំនៅក្នុងទីក្រុងភ្នំពេញនៅតែទន្ទឹងរង់ចាំការវិលត្រឡប់របស់កូនប្រុសទាំងពីរដែលបានបាត់ខ្លួនក្នុងអំឡុងរបបខ្មែរក្រហម ។ គាត់សង្ឃឹមថា កូនៗរបស់គាត់នៅរស់ ។ គាត់សំឡឹងមើលរូបថតកូនប្រុសទាំងពីរនាក់ ដែលគាត់បានថែរក្សាទុកតាំងពីជំនាន់ខ្មែរក្រហម ។ ការចងចាំរបស់គាត់ស្ថិតនៅក្នុងរូបថតនោះ ខណៈដែលគាត់រៀបរាប់សាច់រឿង ។

ក្នុងនាមជាអ្នកស្រាវជ្រាវនិងជាសមាជិកម្នាក់ដែល ស៊ូហ្សាន ខេស៊ី ហៅថាជា «ក្មេងជំនាន់ក្រោយហេតុការណ៍រន្ធត់» ខ្ញុំជឿថា ការស្តាប់សាច់រឿងរបស់អ្នករស់រានមានជីវិតមានសារសំខាន់ណាស់ ។ ខ្ញុំកត់សម្គាល់ឃើញថា អ្នកផ្តល់បទសម្ភាសន៍ត្រូវការ «អ្នកស្តាប់ដែលយល់ចិត្តពួកគាត់» ដើម្បីធ្វើជា សាក្សីទៅលើការចងចាំនិងហៅត្រឡប់មកវិញនូវការបាត់បង់ ប្រមទាំងជួយទទួលស្គាល់នូវការឈឺចាប់របស់គាត់ ។ ដូច្នេះហើយ តួនាទីរបស់អ្នកស្តាប់មានសារសំខាន់ដើម្បីធ្វើឲ្យអ្នកនិយាយរឿងមានអារម្មណ៍ ថាពួកគាត់មិនស្ថិតតែម្នាក់ឯងទេ ប៉ុន្តែមានអ្នកផ្សេងទៀតដែលជួយធ្វើជាសាក្សីនិងជួយបន្ធូរបន្ថយការឈឺចាប់របស់គាត់បានមួយកម្រិត ។ អ្នកស្តាប់ឬអ្នកធ្វើបទសម្ភាសន៍មានតួនាទីដើម្បីធ្វើជាសាក្សីទៅលើ រឿងរ៉ាវដែលអ្នករៀបរាប់ប្រហែលជាមិនអាចទទួលតែម្នាក់ឯងបាន ។ ស៊ូហ្សាណា ហ្វែលម៉ាន និយាយថា «ការទទួលខុសត្រូវរួមគ្នានេះគឺជាប្រភពដើម្បីធ្វើឲ្យការពិតផុសឡើង» ។

ទោះបីជាមានការលំបាកខ្លះ ជនជាតិចាមជាច្រើនមានភាពក្លាហានក្នុងការប្រឈមមុខនឹងអតីតកាល ។ យើងទាំងអស់គ្នាចាំបាច់ថែរក្សាសញ្ញាណដ៏សំខាន់នេះ ។ ប្រជាជនទាំងនេះព្យាយាមព្យាបាលរបួសផ្លូវចិត្តតាមមធ្យោបាយជាច្រើនទាំងតាមផ្លូវសាសនានិងផ្លូវសង្គម ។ តាមរយៈការលើកទឹកចិត្តឲ្យពួកគាត់និយាយចេញមក ហើយនិងស្តាប់ដោយយកចិត្តទុកដាក់ក៏ដូចជាឲ្យពួកគាត់ដឹងពីឥទ្ធិពលនៃ សាច់រឿងរបស់ពួកគាត់ យើងអាចទម្លាយនូវភាពស្ងៀមស្ងាត់ហើយការចងចាំរបស់ពួកគាត់អាចគេចផុត ពីការបំប៉ោងនិងងងឹតស្ងួន ។ ដូច្នេះ កិច្ចខិតខំប្រឹងប្រែងត្រូវតែបន្តដើម្បីអប់រំក្មេងជំនាន់ក្រោយសម្រាប់ គោលបំណងរក្សាការចងចាំ អប់រំនិងទប់ស្កាត់អំពើប្រល័យពូជសាសន៍ ហើយកសាងសង្គមប្រជាធិបតេយ្យដ៏រឹងមាំនៅប្រទេសកម្ពុជា ។

## សេចក្ដីបន្ថែម

សេចក្ដីណែនាំសម្រាប់ការសន្ទនាប្រវត្តិសាស្ត្រតាមការសួរនាំ ៖

ក) ព័ត៌មានទូទៅរបស់បេក្ខជន

១. ឈ្មោះ អាយុ ភេទ

២. ថ្ងៃខែឆ្នាំកំណើតនិងទីកន្លែងកំណើត

៣. មុខងារ និង អង្គការឬស្ថាប័នរបស់បេក្ខជន

៤. ព័ត៌មានទាក់ទង

ខ) ព័ត៌មានរបស់អ្នកផ្ដល់បទសម្ភាសន៍

១. ឈ្មោះ អាយុ ភេទ

២. ថ្ងៃខែឆ្នាំកំណើតនិងទីកន្លែងកំណើត

៣. មុខងារឬមុខរបរ

៤. ព័ត៌មានទាក់ទង

គ) ការជួបជាមួយអ្នកផ្ដល់បទសម្ភាសន៍និងសំណួរ

### ◆អ្នកណាជាអ្នកដែលត្រូវផ្ដល់បទសម្ភាសន៍?

១. ជ្រើសរើសឪពុកឬម្ដាយឬសាច់ញាតិណាម្នាក់របស់អ្នកដើម្បីសរសេរអំពីសាច់រឿងរបស់គាត់

២. មុនពេលចាប់ផ្ដើមសម្ភាសន៍ សូមចាប់ផ្ដើមសួរសំណួរទូទៅនិងជម្រាបគាត់អំពីសារសំខាន់នៃការចែករំលែករបស់គាត់

៣. សូមប្រុងប្រយ័ត្នអំពីបញ្ហារំជួលចិត្តដែលអាចកើតមានឡើងក្នុងពេលសន្ទនា ។ សូមព្យាយាមដោះស្រាយតាមដែលអាចធ្វើទៅបាន (ឆាប់ដឹង ផ្អាកការសម្ភាសន៍មួយរយៈខ្លី និងបង្ហាញពីការយល់ ចិត្តដល់អ្នកដែលយើងសម្ភាសន៍)

ឃ) សំណួរ

◆ **សម្រាប់អ្នកដែលផ្តល់បទសម្ភាសន៍**

១. សូមរៀបរាប់ពីបទពិសោធន៍នៅក្រោមរបបខ្មែរក្រហម ចាប់តាំងពីពេលដែលជម្លៀសរហូតដល់ការ រស់នៅប្រចាំថ្ងៃក្រោមរបបនោះ

២. តើហេតុការណ៍សំខាន់អ្វីខ្លះដែលម៉ាក់ប៉ុប៉ាជួបប្រទះហើយអ្វីទៅជាការចងចាំខ្លាំងដែលមិនអាចបំភ្លេច បាន?

៣. តើម៉ាក់ប៉ុប៉ាធ្លាប់ឮសាលាក្តីខ្មែរក្រហមដែរឬទេ?

៤. តើម៉ាក់ប៉ុប៉ាគិតថា តុលាការអាចជួយព្យាបាលរបួសផ្លូវចិត្តបានដែរឬទេ?

៥. តើអ្វីទៀតដែលគួរធ្វើ ដើម្បីជួយផ្សះរបួសរបស់ម៉ាក់ប៉ុប៉ា?

៦. តើអ្វីដែលម៉ាក់ប៉ុប៉ាចង់បង្រៀនដល់ក្មេងជំនាន់ក្រោយអំពីរបបនោះ?

◆ **សម្រាប់បេក្ខជន**

១. តើអ្នកមានប្រតិកម្មយ៉ាងដូចម្តេចទៅនឹងសាច់រឿងនោះ?

២. តើអ្នកគិតថារបបខ្មែរក្រហមជារបបយ៉ាងដូចម្តេច?

៣. តើពាក្យថាយុត្តិធម៌មានន័យយ៉ាងដូចម្តេច?

៤. តើពាក្យថា ការផ្សះផ្សាមានន័យយ៉ាងដូចម្តេច?

៥. បើតាមគំនិតរបស់អ្នក មានវិធីអ្វីខ្លះដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍?

៦. តើសាលាក្តីខ្មែរក្រហមមានសារសំខាន់យ៉ាងដូចម្តេចខ្លះ?

៧. តើអ្នកយល់ឃើញយ៉ាងដូចម្តេចចំពោះគម្រោងប្រវត្តិសាស្ត្រតាមការសួរនាំនិងកម្មវិធីសម្រាប់ យុវជន ចាម?